ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ដំណើរការនៃការប្រមូលពន្ធលើអចលនទ្រព្យ របស់អគ្គនាយកដ្ឋានពន្ធដារ

# GENERAL DEPARTMENT OF TAXATION’S PROPERTY TAX COLLECTION PROCESS

ជំនាញ៖ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៤

PHNOM PENH-2024

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ដំណើរការនៃការប្រមូលពន្ធលើអចលនទ្រព្យរបស់ អគ្គនាយកដ្ឋានពន្ធដារ

GENERAL DEPARTMENT OF TAXATION’S PROPERTY TAX COLLECTION PROCESS

សាស្ត្រាចារ្យណែនាំ៖ វ៉ាន់ ស្រីនាង

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៤

PHNOM PENH-2024

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២១**
**ប្រធានបទ៖ ដំណើរការនៃការប្រមូលពន្ធលើអចលនទ្រព្យរបស់**
**អគ្គនាយកដ្ឋានពន្ធដារ**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត ស្រេង ផល្លា

សាស្ត្រាចារ្យណែនាំ

វ៉ាន់ ស្រីនាង

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត មាស សំណាង

ប្រធានគណៈកម្មការវាយតម្លៃ និងជាប្រធាន
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

គណៈកម្មការវាយតម្លៃទី៤

បេក្ខបណ្ឌិត យ៉ែម សុខហៀក

**នាយកវិទ្យាស្ថាន**

**បណ្ឌិត ហេង វ៉ាន់ដា**

នាយិការងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគណនេយ្យ នៅវិទ្យាស្ថាន វ៉ាន់ដា អស់រយៈពេល៤ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំ បានទទួលនូវចំណេះដឹងជាច្រើនពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យជាពិសេស ក្រុមយើងខ្ញុំយល់ច្បាស់ថាជំនាញគណនេយ្យគឺជាជំនាញមួយមានសារសំខាន់មួយដែរសម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តីសុទ្ធតែត្រូវអនុវត្តកិច្ចការធនាគារដូចគ្នា។ ដោយឡែកដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់ វិទ្យាស្ថាន វ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធនឹងការងារគណនេយ្យតាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទីមួយរហូតដល់ឆ្នាំសិក្សាទីបួន។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យយល់ច្បាស់ ពីការអនុវត្តការងារធនាគារពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្តការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃ ព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារធនាគារ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំសង្កេតឃើញថា កិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំង ស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំ សម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី “**ដំណើរការនៃការប្រមូលពន្ធលើអចលនទ្រព្យ របស់អគ្គនាយកដ្ឋានពន្ធដារ**” យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណា និងប្រសិទ្ធភាពនៃការផ្តល់ឥណទានរបស់ធនាគារ។ ក្រុមយើងខ្ញុំសង្ឃឹមថាការរៀបចំសារណានេះ នឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដ៏ទៃទៀតដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនានៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ ក្នុងន័យស្ថាបនាដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធក្រុម



រ៉ាត់ បញ្ញារិទ្ធ
ID: HS21/616



សេន ស្រីទូច
ID: HS21/600



អ៊ិញ ស្រីលីកា
ID: HS21/617



ចាយ ពិសី
ID: HS21/602



ធឿន ម៉ាលី
ID: HS21/605

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំ ជានិស្សិតនៃវិទ្យាស្ថាន វ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២១ នៃជំនាញគណនេយ្យ

**សូមសម្តែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិការ និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រ ដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំ សូមសម្តែងនូវការគោរព និងកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់ខ្ញុំបាទ នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ឌាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសម្តែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅ ដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** នាយកនៃវិទ្យាស្ថានវ៉ាន់ដាដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាលព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះសាស្ត្រាចារ្យ **វ៉ាន់ ស្រីនាង** ជាសាស្ត្រាចារ្យដឹកនាំ ដែលបានជួយជ្រោមជ្រែងបង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់នូវកិច្ចការសារណានេះ ចប់ជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ និងបុគ្គលិកនៃវិទ្យាស្ថាន វ៉ាន់ដាទាំងអស់ ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលខាងលើទាំងអស់ ឱ្យជួបតែពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អំណះអំណាង**

ក្រុមយើងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យ នៃវិទ្យាស្ថាន វ៉ាន់ដា ជំនាន់ទី២១៖

សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទ "**ដំណើរការនៃការប្រមូលពន្ធលើអចលនទ្រព្យរបស់អគ្គនាយកដ្ឋានពន្ធដារ**" នេះគឺជាស្នាដៃរបស់ក្រុមខ្ញុំបាទ នាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវដែលលើកឡើង នេះជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃ. ............... ខែ.......... ឆ្នាំ........... ព.ស.២៥៦....

ថ្ងៃទី.......... ខែ.......... ឆ្នាំ២០២....

**ហត្ថលេខាតំណាងក្រុម**

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

យើងបានដឹងហើយថា ពន្ធលើអចលនទ្រព្យត្រូវបានបង្កើតឡើងនៅឆ្នាំ២០១០ នឹងត្រូវបានដាក់ឱ្យអនុវត្តន៍ឆ្នាំ២០១១។ ពន្ធលើអចលនទ្រព្យនេះ បានប្រមូលជាប្រចាំឆ្នាំលើអចលនទ្រព្យ ដែលស្ថិតនៅក្នុងតំបន់ រដ្ឋបាលថ្នាក់ ខេត្ត/ខណ្ឌរាជធានី និងរដ្ឋបាលក្រុងនៅតាមបណ្តាលខេត្តនានាជាមួយនឹងអាត្រា ០.១% នៃតម្លៃអចលនទ្រព្យសរុប ដែលត្រូវបានកំណត់ដោយគណៈគម្មាធិការវាយតម្លៃអចលនទ្រព្យ។នេះមានន័យថា ម្ចាស់អចលនទ្រព្យ ត្រូវស្វ័យប្រកាសបង់ពន្ធនៅរដ្ឋបាលសារពើពន្ធ។ ប្រសិនបើ ម្ចាស់អចលនទ្រព្យមួយចំនួនមានភាពយឺតយ៉ាវ មិនបានបង់ពន្ធគាត់នឹងទទួលរងការពិន័យ តាមបទបញ្ញត្តិដែលមានជាធរមាន។ ប្រសិនបើ ម្ចាស់អចលនទ្រព្យមិនទាន់បានចុះបញ្ជី គាត់ក៏ត្រូវចុះបញ្ជី ឬផ្តល់ព័ត៌មានថ្មីៗ ទាក់ទងទៅនឹងការកែសម្រួលអចលនទ្រព្យ ដែលគាត់មានដើម្បីបង់ពន្ធអោយចូលរួមឱ្យបានត្រឹមត្រូវ។ ក្នុងការវាយតម្លៃនេះផងដែរ ក៏មានការចូលរួមដោយភាគីជាច្រើន រួមទាំងស្ថាប័នឯកជន ដើម្បីធ្វើឱ្យតម្លៃដែលមានកំណត់នោះអាចនឹងទទួលយកបាន។

តាមរយៈការសិក្សាកន្លងមក ក្រុមយើងខ្ញុំបានប្រមូលពន្ធទិន្ន័យ និងការផ្តល់ជូននូវព័ត៌មានផ្សេងៗ ដែលពាក់ព័ន្ធនឹងការប្រមូលពន្ធដើម្បីយកមកប្រៀបធៀបរវាងទ្រឹស្តី និងការអនុវត្តន៍ជាក់ស្តែង។ ទោះបីជាការប្រមូលពន្ធលើអចលនទ្រព្យ ដែលមានចំណុចល្អពិតមែន តែក៏នៅមានចំណុចខ្វះខាតមួយចំនួន ដូចជា បន្តពង្រឹងអនុវត្តន៍ច្បាប់ និងបទបញ្ញត្តិស្តីអំពីពន្ធដារប្រកបដោយភាពទន់ភ្លន់ និងស្មើភាព ដើម្បីជម្រុញដល់អ្នកជាប់ពន្ធ បំពេញកាតព្វកិច្ចបានត្រឹមត្រូវបង្កើតវិធានការតឹងរឹង ចំពោះបុគ្គលគេចវេសការបង់ពន្ធ និងការពន្យាពេលការបង់ពន្ធ ព្រោះចំណូលបានមកពីពន្ធត្រូវយកមកអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ក្នុងប្រទេស និងសង្គមជាតិទាំងមូល។

សរុបសេចក្តីមកយើងឃើញថា ការប្រមូលពន្ធលើអចលនទ្រព្យនៅមានចំណុចល្អ និងចំណុចខ្វះខាតមួយចំនួន ហើយក្រុមយើងខ្ញុំ ក៏បានផ្តល់ជាមតិយោបល់ខ្លះៗ ដើម្បីការប្រមូលពន្ធអចលនទ្រព្យនេះ មានការប្រសើរឡើងជាងមុន។ យ៉ាងណាក៏ដោយ អគ្គនាយកដ្ឋានពន្ធដារនៅតែបំពេញតួនាទីក្នុងការប្រមូលពន្ធលើអចលនទ្រព្យឱ្យបានខ្ជាប់ខ្ជួន និងផ្តល់ភាពងាយស្រួលដល់បុគ្គលដែលជាប់ពន្ធអោយមកបង់ពន្ធលើអចលនទ្រព្យរបស់ខ្លួនតាមការកំណត់។

# មាតិកា

ទំព័រ


អារម្ភកថា ............ i
រចនាសម្ព័ន្ធក្រុម ............ ii
សេចក្ដីថ្លែងអំណរគុណ ............ iii
អំណះអំណាង ............ iv
សេចក្ដីសង្ខេបនៃការស្រាវជ្រាវ ............ v

## ជំពូកទី១
## សេចក្ដីផ្ដើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ............ ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ............ ២
១.តើពន្ធដារមាននិតិវិធីអ្វីខ្លះក្នុងការប្រមូលពន្ធលើអចលនទ្រព្យ?
២.តើយើងត្រូវមានកាតព្វកិច្ចអ្វីខ្លះក្នុងការបង់ពន្ធលើអចលនទ្រព្យ?
១.៣ គោលបំណងនៃការស្រាវជ្រាវ ............ ២
១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ............ ២
១.៤.១ ទំហំដែនកំណត់ ............ ២
១.៤.២ វិសាលភាពនៃការស្រាវជ្រាវ ............ ២
១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ............ ២
១.៥.១ ការប្រមូលទិន្នន័យដំបូង ............ ២
១.៥.២ ការប្រមូលទិន្នន័យបន្ទាប់ ............ ៣
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ............ ៣
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ............ ៣

## ជំពូកទី២
## រំលឹកទ្រឹស្ដី

២.១ លក្ខណៈទូទៅនៃការប្រមូលពន្ធលើអចលនទ្រព្យរបស់ពន្ធដារ
២.១.១ និយមន័យ ............ ៤
២.១.២ ប្រវត្តិពន្ធរបស់សហរដ្ឋអាមេរិក ............ ៤
២.១.៣ ទ្រឹស្ដីនៃការប្រមូលពន្ធលើអចលនទ្រព្យ ............ ៤
២.២ នីតិវិធីនៃការប្រមូលពន្ធ
២.២.១ និយមន័យ ............ ៥
២.២.២ ប្រវត្តិនៃការប្រមូលពន្ធលើអចលនទ្រព្យ ............ ៥
២.២.៣ ទ្រឹស្ដីនៃនីតិវិធីក្នុងប្រមូលពន្ធលើអចលនទ្រព្យ ............ ៦

២.៣ ផលប្រយោជន៍នៃការប្រមូលពន្ធលើអចលនទ្រព្យចំពោះសេដ្ឋកិច្ចជាតិ............................ ៦
២.៣.១ និយមន័យ ........................................................................................................ ៦
២.៣.២ ប្រវត្តិនៃសេដ្ឋកិច្ចជាតិ........................................................................................ ៧
២.៣.៣ ប្រភេទនៃប្រពន្ធសេដ្ឋកិច្ចជាតិ.............................................................................. ៧
ក.សេដ្ឋកិច្ចបែបប្រពៃណី .................................................................................. ៧
ខ.សេដ្ឋកិច្ចបញ្ជាឬសេដ្ឋកិច្ចផែនការ ................................................................... ៨
គ.សេដ្ឋកិច្ចទីផ្សារសេរី........................................................................................ ៨
ឃ.សេដ្ឋកិច្ចចម្រុះ................................................................................................ ៨

## ជំពូកទី៣

## លទ្ធផលនៃការស្រាវជ្រាវ

៣.១ ស្ថានភាពទូទៅក្នុងការប្រមូលពន្ធលើអចលនទ្រព្យរបស់អគ្គនាយកដ្ឋានពន្ធដារ ....................... ៩
៣.១.១ ប្រវត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ........................................................................ ៩
៣.១.២ ចក្ខុវិស័យ បេសកកម្ម គោលដៅ របស់អគ្គនាយកដ្ឋានពន្ធដារ .............................. ១០
ក.ចក្ខុវិស័យ ..................................................................................................... ១០
ខ.បេសកកម្ម...................................................................................................... ១១
គ.គោលដៅ ....................................................................................................... ១២
៣.១.៣ រចនាសម្ព័ន្ធនៃការប្រមូលពន្ធ តួនាទី និងភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ.................... ១៣
ក. រចនាសម្ព័ន្ធនៃការប្រមូលពន្ធ .......................................................................... ១៣
ខ. តួនាទីនៃការប្រមូលពន្ធ .................................................................................. ១៦
គ. ភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ................................................................. ១៧
៣.២ នីតិវិធីក្នុងការប្រមូលពន្ធលើអចលនទ្រព្យរបស់អគ្គនាយកដ្ឋានពន្ធដារ................................ ១៨
៣.២.១ មូលដ្ឋាននិងនីតិវិធីនៃការប្រមូលពន្ធ.................................................................. ១៨
ក.ពន្ធលើអចលនវត្ថុ ........................................................................................... ១៨
ខ.ពន្ធលើដីទំនេរ ឬដីធ្លីមិនបានប្រើប្រាស់ ............................................................. ១៨
គ.ពន្ធប្រថាប់ត្រា (ពន្ធលើការផ្ទេរលើអចលនទ្រព្យ)................................................ ១៨
ឃ.ពន្ធលើឈ្នួលអចលនទ្រព្យ ឬពន្ធលើការជួល ..................................................... ១៨
៣.២.២ ការគ្រប់គ្រងការប្រមូលពន្ធ.................................................................................. ១៩
៣.២.៣ របាយការណ៍ប្រមូលពន្ធ ....................................................................................២៣
៣.៣ ផលប្រយោជន៍នៃការប្រមូលពន្ធលើអចលនទ្រព្យរបស់អគ្គនាយកដ្ឋានពន្ធដារ ........................... ២៥
៣.៣.១ កាតព្វកិច្ចនៃការបង់ពន្ធ ..................................................................................... ២៥
៣.៣.២ ការប្រមូលពន្ធបានផ្តល់ផលប្រយោជន៍ដល់សង្គមនិងសេដ្ឋកិច្ចជាតិ.................... ២៨

## ជំពូកទី៤
## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង.................................................................................. ៣១
៤.២ ការវិភាគលើចំណុចខ្សោយ.................................................................................៣២

## ជំពូកទី៥
## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន .........................................................................................៣៣
៥.២ ការផ្តល់អនុសាសន៍ ....................................................................................... ៣៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

# ជំពូកទី ១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលស្ថិតនៅភាគខាងត្បូងនៃទ្វីបអាស៊ី ដែលមានព្រំប្រទល់ជាប់និងឈូងសមុទ្រប្រទេសថៃហើយនៅចំកណ្តាលរវាងប្រទេសវៀតណាម ប្រទេសថៃ និងប្រទេសឡាវ។ ម្យ៉ាងវិញទៀត ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលសម្បូរទៅដោយសម្បត្តិវប្បធម៌ធម្មជាតិយ៉ាងច្រើនអនេក ប៉ុន្តែដោយសារតែប្រទេសកម្ពុជា ជួបប្រទះនូវសង្គ្រាមអស់រយៈពេលយ៉ាងច្រើនសតវត្សកន្លងមកនេះ ក៏ធ្វើឱ្យខឿនសេដ្ឋកិច្ចជាតិមានការធ្លាក់ចុះយ៉ាងខ្លាំង។ ប៉ុន្តែ បើក្រឡេកមកមើលសព្វថ្ងៃនេះយើងឃើញថាប្រទេសកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍន៍ដែលមានការវិវត្តន៍ និងអភិវឌ្ឍន៍ទៅមុខឥតឈប់ឈរ ដើម្បីឱ្យឈានទៅរកភាពរីកចម្រើនជាបន្តបន្ទាប់។ ប្រទេសកម្ពុជា មានការរីកចម្រើនទៅមុខបាន គឺអាស្រ័យទៅលើការខិតខំប្រឹងប្រែងរបស់ប្រមុខរាជរដ្ឋាភិបាល និងប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ។

ដើម្បីលើកស្ទួយវិស័យសេដ្ឋកិច្ចជាតិ ឱ្យមានភាពរីកលូតលាស់ប្រសើរឡើង និងបង្កើនចំណូលជូនជាតិមាតុភូមិយើង រាជរដ្ឋាភិបាលបានបង្កើតនៅយុទ្ធសាស្ត្រជាច្រើន ដូចជាការបង្កើតប្រព័ន្ធធារាសាស្ត្រសម្រាប់កសិករធ្វើស្រែចំការអោយមានការរីកចម្រើន និងបានលើកស្ទួយវិស័យទេសចរណ៍ឧស្សាហកម្មនិងការប្រមូលពន្ធផ្សេងៗពីសំណាក់ប្រជាជន ក្រុមហ៊ុន និងសហគ្រាស ដើម្បីបង់ថវិការជូនរដ្ឋ ហើយរដ្ឋយកថវិការនោះទៅប្រើប្រាស់ផ្សេងៗទៀត ទៅតាមតម្រូវការរបស់ប្រទេសជាតិ។ បើយោងតាមលិខិតប្រកាសស្តីពីការប្រមូលពន្ធលើអចលនទ្រព្យ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/ រមក/ ១២០៩/ ០២៦ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៩ និងប្រកាសលេខ ៤៩៣ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការប្រមូលពន្ធលើអចលនទ្រព្យក៏ជាផ្នែកមួយដ៏សំខាន់សម្រាប់ជួយដល់ប្រទេសជាតិយើង ផងដែរ ព្រោះថាថវិការដែលបានមករដ្ឋាភិបាលបានយកមកប្រើប្រាស់ក្នុងការស្តារប្រទេស ឱ្យកាន់តែមានសក្តានុពលបន្ថែមទៀត។ ជាក់ស្តែងការប្រមូលពន្ធលើអចលនទ្រព្យនេះមានភាពពិបាកក្នុងការប្រមូលពន្ធ ដូច្នេះហើយទើបពួកគេបានបង្កើតជាយុទ្ធសាស្ត្រផ្សេងៗដើម្បីឱ្យប្រជាពលរដ្ឋយល់ដឹងកាន់តែច្បាស់លាស់ នឹងមានភាពងាយស្រួលក្នុងការអនុវត្តន៍តាមច្បាប់ដែលបានចែងមក។ កាលណាបើប្រជាពលរដ្ឋយល់ដឹងកាន់តែច្រើនអំពីការបង់ពន្ធនោះនឹងធ្វើឱ្យពន្ធដារក៏មានភាពងាយស្រួលក្នុងការប្រមូលពន្ធផងដែរ។ លើសពីនេះទៅទៀត ប្រសិនបើមានការបង់ពន្ធកាន់តែច្រើននោះក៏ធ្វើឱ្យចំណូលជាតិមានការកើនឡើងផងដែរ ហើយប្រជាពលរដ្ឋងាកមកចាប់អារម្មណ៍នូវការបំពេញកាតព្វកិច្ចរបស់ខ្លួនបានយ៉ាងខ្ជាប់ខ្ជួន។

## ១.២ ចំណោទបញ្ហា នៃការស្រាវជ្រាវ

តាមការសិក្សាកន្លងមកបានបង្ហាញ ឱ្យឃើញអំពីអត្ថន័យខ្លឹមសារដែលទាក់ទងទៅនឹងការប្រមូលពន្ធលើអចលនទ្រព្យយកមកធ្វើការសិក្សាស្រាវជ្រាវដើម្បីឆ្លើយតបទៅនឹងសំណួរដូចខាងក្រោម ៖

១. តើពន្ធដារមាននីតិវិធីអ្វីខ្លះក្នុងការប្រមូលពន្ធលើអចលនទ្រព្យ ?

២. តើការប្រមូលពន្ធលើអចលនទ្រព្យបានផ្តល់ផលប្រយោជន៍អ្វីខ្លះដល់សេដ្ឋកិច្ចជាតិ ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះធ្វើឡើង ក្នុងគោលបំណងចង់ឱ្យប្រជាជនទាំងអស់ធ្វើការ ស្វែងយល់ឱ្យកាន់តែច្បាស់អំពីដំណើរការនៃការប្រមូលពន្ធលើអចលនទ្រព្យរបស់អគ្គនាយកដ្ឋានពន្ធដារ។ លើសពីនេះទៅទៀតគឺដើម្បីឱ្យរដ្ឋាភិបាល មានភាពងាយស្រួលក្នុងការប្រមូលពន្ធពីប្រជាពលរដ្ឋ មិនតែប៉ុណ្ណោះការប្រមូលពន្ធនេះវាក៏អាចធ្វើឱ្យសេដ្ឋកិច្ចជាតិ ឆាប់មានការរីកលូតលាស់ទៅមុខថែមទៀតផង។ ជាពិសេសរដ្ឋាភិបាលបានរិះរកមធ្យោបាយថ្មីៗក្នុងការប្រមូលពន្ធដើម្បី ឱ្យកាន់តែមានប្រសិទ្ធិភាពនិងមានភាពប្រសើរជាងមុនទ្វេរដង។ជាការពិតណាស់ ដើម្បីឱ្យប្រជាពលរដ្ឋយល់ដឹងពីកាតព្វកិច្ចរបស់ពួកគាត់ក្នុងការបង់ពន្ធផ្សេងៗ ជូនរដ្ឋផងដែរ។ ហើយការរួមចំណែកនេះនឹងធ្វើឱ្យប្រទេសជាតិកាន់តែមានភាពប្រសើរឡើង។

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំដែនកំណត់

ដោយផ្អែកទៅលើពេលវេលា ប្រធានបទ និងចំណោទបញ្ហាដែលបានចោទសួរខាងលើក្រុមខ្ញុំបាទ/នាងខ្ញុំ បានធ្វើការស្រាវជ្រាវ លើកយកទីតាំងដែលស្ថិតនៅលើ ផ្លូវ១១២ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ ដោយផ្តោតសំខាន់ទៅលើដំណើរការនៃការប្រមូលពន្ធលើអចលនទ្រព្យ និងការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានពន្ធដារ។

### ១.៤.២ វិសាលភាពនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ គឺយើងលើកយកតែចំណុចសំខាន់ ដើម្បីធ្វើការស្វែងយល់ឱ្យកាន់តែច្បាស់ពីតថភាពនៃកាប្រមូលពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ២០២៤ តែប៉ុណ្ណោះ។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

### ១.៥.១ ការប្រមូលទិន្នន័យដំបូង

ចំពោះវិធីសាស្ត្រនៃការស្រាវជ្រាវ គឺមានច្រើនបែបច្រើនយ៉ាងណាស់តែសម្រាប់ការស្រាវជ្រាវទៅលើអត្ថបទខាងលើនេះ ក្រុមខ្ញុំបាទ/នាងខ្ញុំ បានជ្រើសរើសយកវិធីសាស្ត្រពីរបែប ក្នុងការបកស្រាយប្រធានបទខាងលើឱ្យបានក្បោះក្បាយ ដំបូងគឺយកវិធីសាស្ត្របែបពិពណ៌នាមកធ្វើការប្រើប្រាស់ ដើម្បីឱ្យកាន់តែមានភាពងាយស្រួល ម្យ៉ាងវិញទៀតយើងក៏បានលើកយកវិធីសាស្ត្របែបរុករកមកនិយាយផងដែរ ដើម្បីឱ្យកាន់តែច្បាស់លាស់ជាងមុនបន្ថែមទៀត។

**១.៥.២ ការប្រមូលទិន្នន័យបន្ទាប់**

វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ ដើម្បីសិក្សាស្រាវជ្រាវអំពីប្រធានបទដំណើរការ នៃការប្រមូលពន្ធលើអចលនទ្រព្យរបស់អគ្គនាយកដ្ឋានពន្ធដារ យើងបានរៀបចំផែនការខាងក្រោម ៖

- ទិន្នន័យទី១
- ដោយមានការចុះទៅធ្វើការសាកសួរព័ត៌មានដោយផ្ទាល់ជាមួយអ្នកដែលធ្វើការនៅពន្ធដារ
- នឹងធ្វើការសាកសួរព័ត៌មានដោយផ្ទាល់ជាមួយផ្នែកដែលពាក់ព័ន្ធផងដែរ។
- ទិន្នន័យទី២
- ទទួលបានឯកសារដែលតម្កល់ទុកនៅក្នុងបណ្ណាល័យនៃ វិទ្យាស្ថានវ៉ាន់ដា
- ទទួលបានឯកសារពីការសិក្សាស្រាវជ្រាវ តាមរយៈប្រព័ន្ធ អ៊ីនធឺណេត(Internet)
- ទទួលបានការផ្តល់យោបល់ពីសំណាក់សាស្ត្រាចារ្យដឹកនាំ
- ទទួលបានឯកសារពីវេបសាយអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

តាមការសិក្សាស្រាវជ្រាវនេះបានឆ្លុះបញ្ចាំងអំពីសារៈសំខាន់ និងអត្ថប្រយោជន៍ជាច្រើន ៖

- ទទួលបានបទពិសោធន៍ដែលបង្កលក្ខណៈងាយស្រួលក្នុងការស្វែងរកការងារ
- ធ្វើឱ្យអ្នកស្រាវជ្រាវយល់ដឹងអំពីការងាររបស់អគ្គនាយកដ្ឋានពន្ធដារ
- ធ្វើឱ្យយើងដឹងពីការរៀបចំរចនាសម្ព័ន្ធ ក៏ដូចជាភារកិច្ចរបស់បុគ្គលិកនៅក្នុងក្រុមហ៊ុន
- អាចរក្សាទុកជាឯកសារដល់និស្សិតជំនាន់ក្រោយបានយល់ដឹង
- អាចបង្កើតនូវចំណេះដឹងឱ្យកាន់តែទូលំទូលាយ នឹងទទួលបានបទពិសោធន៍ថ្មី...។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

- **ជំពូកទី១ ៖ សេចក្តីផ្តើមរួមមាន**(លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហា គោលបំណង ទំហំ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ)។
- **ជំពូកទី២ ៖ រំលឹកទ្រឹស្តីរួមមាន**(លក្ខណៈទូទៅនៃការប្រមូលពន្ធលើអចលនទ្រព្យ ប្រវត្តិពន្ធរបស់សហរដ្ឋអាមេរិក ទ្រឹស្តីនៃការប្រមូលពន្ធលើអចលនទ្រព្យ នីតិវិធីនៃការប្រមូលពន្ធលើអចលនទ្រព្យ ប្រវត្តិនៃការប្រមូលពន្ធលើអចលនទ្រព្យ ទ្រឹស្តីនីតិវិធីនៃការប្រមូលពន្ធលើអចលនទ្រព្យ ផលប្រយោជន៍នៃការប្រមូលពន្ធលើអចលនទ្រព្យចំពោះសេដ្ឋកិច្ចជាតិ ប្រវត្តិនៃសេដ្ឋកិច្ចជាតិ ទ្រឹស្តីនៃសេដ្ឋកិច្ចជាតិ)។
- **ជំពូកទី៣ ៖ លទ្ធផលនៃការស្រាវជ្រាវស្ថានភាពទូទៅក្នុងការប្រមូលពន្ធលើអចលនទ្រព្យ រួមមាន**(ប្រវត្តិសង្ខេប រូបសញ្ញា ចក្ខុវិស័យ បេសកកម្ម គោលដៅ រចនាសម្ព័ន្ធនៃការប្រមូលពន្ធ តួនាទីនៃការប្រមូលពន្ធ ភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ)។
- **ជំពូកទី៤ ៖ វិភាគចំណុចខ្លាំង និងចំណុចខ្សោយ**
- **ជំពូកទី៥ ៖ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍**

# ជំពូកទី២
# រំលឹកទ្រឹស្តី

# ជំពូកទី ២
# ដំណើរការនៃការប្រមូលពន្ធលើអចលនទ្រព្យ

## ២.១ លក្ខណៈទូទៅនៃការប្រមូលពន្ធលើអចលនទ្រព្យ

### ២.១.១ និយមន័យ

អចលនទ្រព្យ គឺជាដី និងទ្រព្យសម្បត្តិផ្សេងទៀតដែលនៅជាប់ជាមួយដី ដែលមានលក្ខណៈស្ថិតស្ថេរ ដូចជា អគារ លំនៅឋាន ខុនដូរ អគារពាណិជ្ជកម្ម បន្ទប់ស្នាក់នៅ និងសិទ្ធិទាំងឡាយណាដែលពាក់ព័ន្ធ និងកម្មសិទ្ធិដី រួមទាំងប្លង់ដី។

អចលនទ្រព្យ គឺជាទ្រព្យទាំងឡាយណាដែលមានរូបតែគ្មានវិញ្ញាណ ឬទ្រព្យសម្បត្តិមិនមានចលនា អចលនទ្រព្យទាំងឡាយនោះរួមមានដូចជា ដី ផ្ទះ អគារ រថយន្ត ឧបករណ៍ប្រើប្រាស់ផ្សេងៗទៀត បូករួមបញ្ចូលទាំងទ្រព្យសម្បត្តិធម្មជាតិ ដែលមាននៅលើផែនដី និងក្នុងដី។

អចលនទ្រព្យ គឺជាទ្រព្យដែលមានចំនួនកំណត់ និងមិនអាចបំផ្លាញបានដូចដែលពាក្យទូទៅតែងតែលើកឡើងថា មនុស្សចេះតែកើត តែដីមិនចេះកើតទេ។

### ២.១.២ ប្រវត្តិពន្ធរបស់សហរដ្ឋអាមេរិក

ក្នុងអំឡុងពេលសង្គ្រាមស៊ីវិលពីឆ្នាំ១៨៦១ ដល់ឆ្នាំ១៨៦៥ រដ្ឋាភិបាលនៃសហរដ្ឋអាមេរិកបានដឹងថា ពន្ធដារ នឹងមិនអាចប្រមូលពន្ធលើអចលនទ្រព្យបានគ្រប់គ្រាន់ដើម្បីជាដំណើរការឱ្យរដ្ឋាភិបាល នឹងបានធ្វើសឹកសង្គ្រាមប្រឆាំងនឹងសហព័ន្ធបានទេ។ ដូច្នេះហើយនៅឆ្នាំ១៨៦២ សភាបានបង្កើតពន្ធលើអចលនទ្រព្យមានកម្រិត ទៅលើតែបុគ្គលណាដែលមានទឹកប្រាក់ចំនួនច្រើនជាង ៦០០ដុល្លារ ប៉ុន្តែបានច្រានចោលទៅវិញនៅឆ្នាំ១៨៧២ ដើម្បីគាំទ្រដល់ការបង្កើតពន្ធលើថ្នាំជក់ និងគ្រឿងស្រវឹង។ ដូច្នេះហើយសមាជ បានបង្កើតពន្ធលើអចលនទ្រព្យឡើងវិញក្នុងឆ្នាំ១៨៩៤ ប៉ុន្តែដោយសារតុលាការកំពូលប្រកាសមិនយល់ស្របទៅតាមរដ្ឋធម្មនុញ្ញក្នុងឆ្នាំ១៨៩៥។

### ២.១.៣ ទ្រឹស្តីនៃការប្រមូលពន្ធលើអចលនទ្រព្យ

ពន្ធដារ គឺជារូបភាពមួយនៃការបែងចែកឡើងវិញនូវវិការជាតិ ដែលរដ្ឋាភិបាលប្រើប្រាស់ដើម្បីធ្វើការប្រមូលចំណូលពន្ធមួយផ្នែក ពីគ្រប់សមាសភាពសេដ្ឋកិច្ចដែលធ្វើ ការផ្សាភ្ជាប់ជាមួយនឹងសិទ្ធិនយោបាយបានវិភាគទានទាំងរូបវន្តបុគ្គល និងនីតិបុគ្គល។

ពន្ធ គឺជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋ និងគ្រប់សមាសភាព សេដ្ឋកិច្ចត្រូវបង់ជូនរដ្ឋទៅតាមច្បាប់កំណត់ ។ រដ្ឋអាចប្រើប្រាស់មធ្យោបាយពន្ធ ដើម្បីលើកទឹកចិត្តដល់សកម្មភាពសេដ្ឋកិច្ចណាដែលរដ្ឋយល់ថាគួរលើកស្ទួយ និងជម្រុញដើម្បីការអភិវឌ្ឍសេដ្ឋកិច្ច និងផលប្រយោជន៍ប្រជាជនរបស់ប្រទេសខ្លួន ។

ពន្ធដារ ពន្ធ ពន្ធអាករ គឺជាកាតព្វកិច្ចរបស់រូបវន្តបុគ្គល និងនិតិបុគ្គលទាំងអស់ដែលមានចែង ក្នុងក្រិតច្បាប់ ត្រូវតែចូលរួមបង់វិភាគទានជូនទៅកាន់រដ្ឋក្រោមរូបភាពរួមភាពជាការប្រមូលចំណូលជាតិ ដើម្បីឱ្យរដ្ឋាភិបាលធ្វើការបែងចែកចំណូលឡើងវិញសម្រាប់ជាប្រយោជន៍ដល់សង្គមជាតិទាំងមូល មានន័យថារដ្ឋមិនផ្តល់សេវាកម្មទៅអោយ អ្នកបង់ពន្ធទាំងនោះដោយផ្ទាល់វិញឡើយ ហើយអ្នកមានចំណូលតិចបង់ពន្ធតិចអ្នកមានចំណូលច្រើនបង់ពន្ធច្រើន។

តាមទស្សនៈរបស់លោក Charles.M.Allan ពន្ធដារគឺជាលំហូរនៃទ្រព្យសម្បត្តិឯកជនទៅកាន់រដ្ឋ លើកលែងតែជាប្រាក់កម្ចីនិងការលក់សេវាកម្មសាធារណៈរបស់រដ្ឋ។

ចំពោះទស្សនៈរបស់លោក E.R.A.Seligman ពន្ធដារគឺជាអ្វីៗដែលរដ្ឋធ្វើការកំណត់ប្រមូលពីរាស្ត្រ ដើម្បីនាំមកប្រើប្រាស់ជាប្រយោជន៍ដល់សង្គមជាតិ ដោយមិនចំពោះបុគ្គលណាមួយឡើយរួមទាំងអ្នកជាប់ពន្ធផងដែរ។

## ២.២ នីតិវិធីនៃការប្រមូលពន្ធលើអចលនទ្រព្យ

### ២.២.១ និយមន័យ

នីតិវិធី គឺជាបែបបទជាផ្លូវការ ក្នុងការធ្វើអ្វីមួយដោយសេរីនៃសកម្មភាព ដែលប្រព្រឹត្តទៅតាមលំដាប់លំដោយមួយចំនួន។

នីតិវិធី គឺជាវិធីចាត់ចែងដែលច្បាប់បានកំណត់អំពីរបៀបដែលតុលាការប្រើប្រាស់ដើម្បីចាត់ចែងរឿងក្តីតាំងពីដើមរហូតដល់ចប់។

នីតិវិធី គឺជាវិធាននិងវិធីសាស្ត្រលើកិច្ចដំណើរការនៃបណ្តឹងមួយដោយគិតទាំងការជជែកដេញដោលការបង្ហាញភស្តុតាង និង សិទ្ធិរបស់អ្នកចូលរួមក្នុងនីតិវិធីនោះតាមលំដាប់លំដោយនៃវិធានរបស់ច្បាប់។

### ២.២.២ ប្រវត្តិនៃការប្រមូលពន្ធលើអចលនទ្រព្យ

ពន្ធលើអចលនទ្រព្យត្រូវបានបង្កើតឡើងនៅឆ្នាំ២០១០នឹងត្រូវបានដាក់ឱ្យអនុវត្តន៍នៅ ឆ្នាំ២០១១។ ពន្ធអចលនទ្រព្យនេះប្រមូលជាប្រចាំឆ្នាំលើអចលនទ្រព្យ ដែលស្ថិតនៅក្នុងតំបន់ រដ្ឋបាលថ្នាក់ ខេត្ត/ខណ្ឌ រាជធានីភ្នំពេញ និងរដ្ឋបាលក្រុងនៅតាម បណ្តាខេត្តនានាជាមួយ នឹងអត្រា ០.១% នៃតម្លៃអចលនទ្រព្យសរុប ដែលត្រូវបានកំណត់ដោយគណៈកម្មាធិការ វាយតម្លៃអចលនទ្រព្យ។ ក្នុងការវាយតម្លៃនោះដែរ ក៏មានការចូលរួមដោយភាគីជាច្រើន រួមទាំងស្ថាប័នឯកជន ដើម្បីធ្វើឱ្យតម្លៃដែលកំណត់នោះអាចទទួលយកបាន។

ចាប់តាំងពីឆ្នាំ២០១១ រដ្ឋាភិបាលចាប់ផ្តើមអនុវត្តន៍លើច្បាប់ពន្ធលើអចលទ្រព្យដោយចាប់ផ្តើមប្រមូលពន្ធលើអចលនទ្រព្យទាំងអស់នៅតាមទីតាំងសំខាន់ៗ នៅក្នុងប្រទេសកម្ពុជា។ ក្នុងខណៈពេលដែលពន្ធលើអចលនទ្រព្យត្រូវបានដាក់ឱ្យអនុវត្តន៍ វិស័យអចលនទ្រព្យនៅកម្ពុជា មានការកើនឡើងគួរឱ្យកត់សម្គាល់ ដែលជាទូទៅត្រូវបាន គេមើលឃើញថាមានសន្ទុះកំណើនស្ទើរតែគ្រប់ទីកន្លែងក្នុងប្រទេស។

### ២.២.៣ ទ្រឹស្តីនៃនីតិវិធីក្នុងការប្រមូលពន្ធលើអចលនទ្រព្យ

ពន្ធលើអចលនទ្រព្យ គឺជាប្រភេទពន្ធផ្ទាល់ដែលត្រូវបានប្រមូលជាប្រចាំឆ្នាំទៅលើអចលនទ្រព្យដែលស្ថិតនៅភូមិសាស្ត្ររដ្ឋបាលទាំងឡាយណាដែលជាប់ពន្ធ។ ជាគោលការណ៍ ពន្ធលើអចលនទ្រព្យមានវិសាលភាព នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ ក៏ប៉ុន្តែ ជាជំហានដំបូង ច្បាប់បានកំណត់យកពន្ធតែទៅលើអចលនទ្រព្យដែលស្ថិតនៅក្នុងភូមិសាស្ត្រ រដ្ឋបាលរាជធានីភ្នំពេញ និងក្នុងក្រុង នៃខេត្តនានាតែប៉ុណ្ណោះ។ដូចនេះមានន័យថា អចលនទ្រព្យ ដែលនៅតាមភូមិ ឃុំ ស្រុក ដែលនៅក្រៅក្រុង ( ក្រៅទីរួមខេត្ត ) មិនទាន់ត្រូវជាប់ពន្ធដារខេត្ត ឬសាខាពន្ធដារខណ្ឌ ( នៅរាជធានីភ្នំពេញ ) ដែលអចលនទ្រព្យស្ថិតនៅឬបង់តាមប្រព័ន្ធធនាគារ ។ ពន្ធនេះត្រូវបង់យ៉ាងយូរបំផុត ត្រឹមថ្ងៃទី៣០ ខែកញ្ញានៃឆ្នាំជាប់ពន្ធ។

ពន្ធលើអចលនទ្រព្យ ជាប្រភេទពន្ធស្វ័យប្រកាសដោយម្ចាស់អចលនទ្រព្យ ត្រូវបំពេញព័ត៌មានអចលនទ្រព្យ ពាក្យស្នើសុំចុះបញ្ជីពន្ធលើអចលនទ្រព្យ លិខិតប្រកាសបង់ពន្ធលើអចលនទ្រព្យ និងគណនា

ព្រមទាំងបង់ប្រាក់ពន្ធដោយខ្លួនឯង។ ពន្ធលើអចលនទ្រព្យនេះត្រូវប្រមូលដោយរដ្ឋបាលសារពើពន្ធ និងបានបង់ចូលទៅក្នុងគណនីគោលនៃធនាគារជាតិ ដើម្បីជាគុណប្រយោជន៍ទៅដល់ថវិការរដ្ឋបាលថ្នាក់ក្រោមជាតិ (រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ/ឃុំ/សង្កាត់) សម្រាប់ការអភិវឌ្ឍន៍មូលដ្ឋាន។

## ២.៣ ផលប្រយោជន៍នៃការប្រមូលពន្ធលើអចលនទ្រព្យចំពោះសេដ្ឋកិច្ចជាតិ

### ២.៣.១ និយមន័យ

សេដ្ឋកិច្ច គឺជាសំណុំនៃទំនាក់ទំនង ផលិតកម្ម ការប្រើប្រាស់ ការទិញដូរ ការបែងចែងធនធានដ៏កម្រទាំងឡាយ នៅក្នុងសង្គម ឬក៏ទាក់ទងទៅនឹងមីក្រូសេដ្ឋកិច្ច និង ម៉ាក្រូសេដ្ឋកិច្ច។

សេដ្ឋកិច្ច គឺជាការសិក្សាអំពីមនុស្សជាតិនៅក្នុងការងារ ជំនួញធម្មតានៃជីវិតរស់នៅ ដែលទាក់ទងទៅនឹងប្រព័ន្ធផលិតកម្ម (ផ្នែកសេដ្ឋកិច្ចនិងឧស្សាហកម្ម) ប្រព័ន្ធបែងចែក (ផ្នែកពាណិជ្ជកម្ម) និងប្រព័ន្ធប្រើប្រាស់ទំនិញសេដ្ឋកិច្ច (ផ្នែកអតិថិជន ផ្នែកគមនាគមន៍និងដឹកជញ្ជូន)។

តាមទ្រឹស្តីសេដ្ឋវិទូបានឱ្យនិយមន័យ សេដ្ឋកិច្ចខុសៗគ្នាជាច្រើន ប៉ុន្តែន័យសុក្រឹតមួយ គឺសេដ្ឋកិច្ចមានន័យថា ជាកាសិក្សាអំពីការប្រើប្រាស់បណ្តា ធនធានដ៏កម្រដើម្បីបំពេញសេចក្តីត្រូវការរបស់មនុស្សដែលគ្មានព្រំដែន។

### ២.៣.២ ប្រវត្តិនៃសេដ្ឋកិច្ចជាតិ

សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបានឆ្លងកាត់ការអភិវឌ្ឍន៍ចំនួន ៣ដំណាក់កាល ដូចជាការស្តារឡើងវិញពីឆ្នាំ១៩៩៣ ដល់ឆ្នាំ១៩៩៨ ដំណាក់កាលស្ថាបនាឡើងវិញ ពីឆ្នាំ១៩៩៩ ដល់ឆ្នាំ២០០៣ និងដំណាក់កាលសេដ្ឋកិច្ចចាប់ផ្តើមរីកចម្រើន ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៨។ នៅក្នុងដំណាក់កាលស្តារឡើងវិញ ការងារសេដ្ឋកិច្ចផ្តោតសំខាន់ទៅលើការអនុវត្តន៍លើ កំណែទម្រង់ទីផ្សារដើម្បីប្រែក្លាយសេដ្ឋកិច្ចឱ្យក្លាយជាសេដ្ឋកិច្ចទីផ្សារ។ នៅក្នុងដំណាក់កាលស្ថាបនាឡើងវិញ រដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់ទៅលើការស្តារឡើងវិញនូវសន្តិភាព ការធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ ពិភពលោក នឹងការលើកកម្ពស់ការអភិវឌ្ឍន៍សង្គមនិងសេដ្ឋកិច្ចជាតិ។ នៅក្នុងដំណាក់កាលនេះ ផលិតផលក្នុងស្រុកសរុបពិត មានកំណើន ៨.៨ភាគរយជាមធ្យមក្នុងមួយឆ្នាំៗ ដោយមានការជម្រុញពីវិស័យកាត់ដេរ សំណង់ និងទេសចរណ៍ បន្ថែមពីលើនេះទៀតវិស័យកសិកម្ម ដែលជាវិស័យចម្បងជាងគេ។

នៅដំណាក់កាលចាប់ផ្តើមមានសកម្មភាពសេដ្ឋកិច្ច រដ្ឋាភិបាលបានចាប់ផ្តើមកំណែទម្រង់នៅជំនាន់ទី ២ របស់ខ្លួនជាពិសេស ការអនុវត្តន៍កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ការវិនិយោគលើវិស័យសង្គម និងហេដ្ឋារចនាសម្ព័ន្ធត្រូវបានបង្កើត ដើម្បីជួយកាត់បន្ថយភាពក្រីក្រ ជាពិសេស នៅតាមតំបន់ជនបទ។ កំណើនជាមធ្យមមានកម្រិត ១០.៣% ក្នុងមួយឆ្នាំដោយសារមានការជម្រុញពីវិស័យកំណើនចំនួន ៤ មានជាអាទិ៍ វិស័យកាត់ដេរ ទេសចរណ៍ សំណង់និងកសិកម្ម។ ជាមួយនឹងកំណើនដ៏រឹងមាំជាមធ្យម ៩.១% ចាប់ពីឆ្នាំ ១៩៩៨ ដល់ ២០០៨ (GDP) សម្រាប់ប្រជាជនម្នាក់ គិតក្នុងតម្លៃបច្ចុប្បន្ន បានកើនឡើងជិត ៣ ដង ពី ២៥៦ ដុល្លារ នៅក្នុងឆ្នាំ ១៩៩៨ ដល់ ៧៣៨ ដុល្លារ នៅក្នុងឆ្នាំ ២០០៨ ហើយអត្រានៃភាពក្រីក្របានថយចុះមក ៣៥% នៅក្នុងឆ្នាំ ២០០៤ មកនៅប្រហែលជា ៣០% នៅក្នុងឆ្នាំ ២០០៧ ។

### ២.៣.៣ ប្រភេទនៃប្រព័ន្ធសេដ្ឋកិច្ចជាតិ

ប្រព័ន្ធសេដ្ឋកិច្ចគឺជា ប្រព័ន្ធនៃផលិតកម្ម ការលែលកធនធាន និងការបែងចែកទំនិញឬសេវាកម្មនៅក្នុងសង្គមឬទីតាំងភូមិសាស្ត្រជាក់លាក់ណាមួយ។ វាក៏យោងទៅតាមប្រព័ន្ធនៃសង្គមផងដែរដើម្បីកត់សម្គាល់ទៅលើចំណុចអាទិភាពមួយចំនួន ដែលសង្គមនៅអាចសម្រេចបានក្នុងគោលបំណងបង្កើតនូវយុទ្ធសាស្ត្រសេដ្ឋកិច្ចដ៏មានប្រសិទ្ធិភាពនិង ទទួលបានភាពជោគជ័យ។ ប្រព័ន្ធនៃសេដ្ឋកិច្ចត្រូវកំណត់ថាអ្វីៗដែលគេត្រូវផលិត ផលិតដោយរបៀបណា និងផលិតទៅឱ្យអ្នកណា។ យ៉ាងណាមិញប្រព័ន្ធនៃសេដ្ឋកិច្ចត្រូវបានគេបែងចែកជា៤បែប ៖

### ក. សេដ្ឋកិច្ចបែបប្រពៃណី

សេដ្ឋកិច្ចបែបប្រពៃណី គឺជាសេដ្ឋកិច្ចដើមមួយដែលប្រពៃណី ទំនៀមទម្លាប់ និងជំនឿរបស់គ្រួសារសហគមន៍ ក្រុមកុលសម្ព័ន្ធ ឬសាសនារបស់ខ្លួននឹងកំណត់ពីទំនិញ ឬសេវាកម្មដែលសេដ្ឋកិច្ចនោះត្រូវផលិតនិងចែកចាយហើយភាគច្រើនការដោះដូរទំនិញគឺមិនប្រើប្រាស់លុយកាក់។ ប្រទេសដែលប្រើប្រាស់សេដ្ឋកិច្ចរបៀបនេះភាគច្រើនគឺស្ថិតនៅតំបន់ដាច់ស្រយាលនិងពឹងផ្អែកទៅលើវិស័យកសិកម្មជាចម្បង។ គេអាចហៅម្យ៉ាងទៀតថា« ភាពគ្រប់គ្រាន់សម្រាប់ចិញ្ចឹមជីវិត »។សេដ្ឋកិច្ចរបៀបនេះគឺមិនសូវមានឬគ្មានការអភិវឌ្ឍន៍ទទួលយកបច្ចេកវិទ្យា និងផ្អែកសុខាភិបាលពីបរទេសតិចតួចឬគ្មានសោះដោយប្រពៃណី នឹងសម្រេចបានពីការចិញ្ចឹមជីវិតការស្លៀកពាក់ ក៏ដូចជាការតាំងទីលំនៅរបស់ពួកគេដែលប្រព្រឹត្តទៅតាមមនុស្សជំនាន់មុនៗ។ ប៉ុន្តែវាមានលក្ខណៈប្រសើរត្រង់ថាសេដ្ឋកិច្ចបែបនេះនឹងជួយឱ្យប្រជាជននៅតែរក្សាប្រពៃណី ទំនៀមទម្លាប់និងបំពេញចិត្តមនុស្សជុំវិញបានស្របពេលដែលសេដ្ឋកិច្ចផ្សេងទៀតពិបាកនឹងធ្វើបាន។

### ខ. សេដ្ឋកិច្ចបញ្ជាឬសេដ្ឋកិច្ចផែនការ

សេដ្ឋកិច្ចរបៀបនេះគឺរដ្ឋមានសិទ្ធិកាន់កាប់ទៅលើសកម្មភាពទាំងស្រុងនៃសេដ្ឋកិច្ច ដោយការសម្រេចចិត្តចែកចាយនិងផលិតគឺធ្វើទៅតាមផែនការរបស់រដ្ឋាភិបាល។ វាក៏មិនសូវមានភាពបត់បែនដូចជាសេដ្ឋកិច្ចទីផ្សារទេហើយប្រតិកម្មផ្លាស់ប្តូរការទិញទំនិញរបស់អ្នកប្រើប្រាស់ និងភាពឡើងចុះនៃការផ្គត់ផ្គង់នឹងតម្រូវការក៏មានភាពយឺតយ៉ាវផងដែរ។ ឧទាហរណ៍ ដូចជាប្រទេសដែលកាន់របបកុម្មុនីស។ ហេតុផលចម្បងដែលរដ្ឋាភិបាលជ្រើសរើសសេដ្ឋកិច្ចប្រភេទនេះគឺដើម្បីអាចកាន់កាប់ធនធានដែលមានតម្លៃរបស់ខ្លួន ( ឧ. ប្រេង រ៉ែមាស )។ រីឯផ្នែកផ្សេងទៀតដូចជាកសិកម្មគឺប្រជាជនជាអ្នកដឹកនាំនិងចាត់ចែង។

### គ. សេដ្ឋកិច្ចទីផ្សារសេរី

រាល់សកម្មភាពនៃការដោះដូរទំនិញ ដោយសេរីនឹងអាស្រ័យទៅលើការត្រូវរ៉ូវគ្នារវាងអ្នកប្រើប្រាស់និងអ្នកផ្គត់ផ្គង់។ ក្រុមហ៊ុនក៏ដូចជាស្ថាប័នឯកជនមានសិទ្ធិកាន់កាប់ក្រុមហ៊ុន ដាក់តម្លៃទំនិញ គ្រប់គ្រងសង្វាក់ផលិតកម្ម ក៏ដូចជាបុគ្គលិកដោយខ្លួនឯង។ ចំណែករដ្ឋាភិបាលមិនមានសិទ្ធិគ្រប់គ្រងធនធានចាំបាច់ ទំនិញដែលមានតម្លៃ ឬវិស័យសំខាន់ៗនៃសេដ្ឋកិច្ចនោះទេ។ ប្រជាជនជាអ្នកកំណត់ថាសេដ្ឋកិច្ចត្រូវប្រព្រឹត្តទៅដោយរបៀបណា ការផ្គត់ផ្គង់ធ្វើដូចម្តេច និងតម្រូវការអ្វីខ្លះដែលចាំបាច់។ ជាក់ស្តែងមិនមានសេដ្ឋកិច្ចទីផ្សារសេរីសុទ្ធសាធនៅក្នុងពិភពលោកឡើយ។ រដ្ឋាភិបាលនៅតែមានចំណែកចំពោះសេដ្ឋកិច្ចខ្លះៗដដែលៗ។

### ឃ. សេដ្ឋកិច្ចចម្រុះ

ជាសេដ្ឋកិច្ចមួយដែលរួមបញ្ចូល កិច្ចសហប្រតិបត្តិការរវាងសេដ្ឋកិច្ចទីផ្សារ និងសេដ្ឋកិច្ចផែនការជាមួយគ្នា។ធនធានត្រូវបានគេបែងចែកទៅឱ្យទាំងឯកជន និងរដ្ឋាភិបាលជាអ្នកត្រួតត្រាតាមវិស័យនីមួយៗ

ដែលប្រើប្រាស់ គោលការណ៍ល្អបំផុតចំពោះប្រព័ន្ធទាំងពីរ។ ទីផ្សារសេរីគឺមានតិចឬច្រើនជាងរដ្ឋាភិបាល លើកលែងតែវិស័យសំខាន់ៗមួយចំនួនទៀតដូចជា វិស័យអប់រំ ថាមពល( ឧ. អគ្គិសនីកម្ពុជា) ទូរគមនាគមន៍ជាដើម។វិស័យទាំងនោះមិនអាចប្រគល់ឱ្យឯកជនកាន់កាប់ទាំងស្រុងបាននោះទេ ព្រោះវាអាចធ្វើឱ្យប៉ះពាល់ដល់សន្តិសុខជាតិ។ ជាក់ស្តែងយើងឃើញថាវិស័យផ្សេងៗគឺមានទាំងរដ្ឋនិងឯកជន ( ឧ. វិស័យអប់រំ )។ ទោះបីជាតាមទ្រឹស្តីគឺគេចង់ធ្វើយ៉ាងណាឱ្យ វិស័យទាំងពីរអាចទាញយកផលប្រយោជន៍ពីគ្នា ទៅវិញទៅមកឱ្យបានល្អយ៉ាងណាក៏ដោយប៉ុន្តែចំពោះការអនុវត្តន៍ជាក់ស្តែងគឺមិនងាយនោះឡើយ។ យើងឃើញថាទំហំនៃការគ្រប់គ្រងរបស់រដ្ឋាភិបាលគឺធំដែលជួនការអាចមានឥទ្ធិពលលើសពីភាពចាំបាច់ទៅទៀត។

# ជំពូកទី៣
# លទ្ធផលស្រាវជ្រាវ

# ជំពូកទី ៣
# ដំណើរការនៃការប្រមូលពន្ធលើអចលនទ្រព្យ របស់អគ្គនាយកដ្ឋានពន្ធដារ

## ៣.១ ស្ថានភាពទូរទៅក្នុងការប្រមូលពន្ធលើអចលនទ្រព្យរបស់អគ្គនាយកដ្ឋានពន្ធដារ

### ៣.១.១ ប្រវត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ



រូបភាពទី ១ ៖ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- **ប្រវត្តិរបស់អង្គភាពពន្ធដារ**

- នៅឆ្នាំ១៩៥៣ : ត្រូវបានបង្កើតឡើងដោយនាយកដ្ឋានពន្ធដារ
- នៅឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ : ពន្ធដាត្រូវលុបបំបាត់ចោលដោយរបបប៉ុលពត
- នៅឆ្នាំ១៩៨០ : នាយកដ្ឋានពន្ធដារត្រូវបានបង្កើតឡើងវិញ
- ឆ្នាំ២០០៨:នាយកដ្ឋានពន្ធដារបានដំឡើងទៅជាអគ្គនាយកដ្ឋានពន្ធដារដោយសាលាជាតិពន្ធដារ។

### ៣.១.២ ចក្ខុវិស័យ បេសកកម្ម គោលដៅ របស់អគ្គនាយកដ្ឋានពន្ធដារ

### ក. ចក្ខុវិស័យ




**រូបភាពទី ២ ៖ ការវាយតម្លៃយុទ្ធសាស្ត្រកៀរគរចំណូល**

ចក្ខុវិស័យនៃយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ គឺផ្សាភ្ជាប់នឹងចក្ខុវិស័យនៃការអភិវឌ្ឍន៍ប្រទេសកម្ពុជា ដោយពឹងផ្អែកទៅលើការប្រមូលចំណូលក្នុងស្រុកឱ្យមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ដើម្បីឆ្លើយតបឱ្យបានសមស្របទៅនឹងតម្រូវការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមប្រកបដោយចីរភាព។ កម្ពុជាមានចក្ខុវិស័យសម្រេច ឱ្យបាននូវឋានៈ ជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ ដោយចំណូលសម្រាប់ប្រជាជនម្នាក់ៗក្នុងមួយឆ្នាំនឹងកើនឡើងដល់ រង្វង់ ៤.០០០ ទៅ ៥.០០០ ដុល្លារអាមេរិកនៅឆ្នាំ ២០៣០ តាមរយៈការធានាឱ្យបាននូវកំណើនសេដ្ឋកិច្ច ដែលមាន មូលដ្ឋានរឹងមាំ និងភាពធន់ខ្ពស់ សមធម៌នៃការបែងចែកផ្លែផ្កានៃកំណើន ការពង្រឹងស្ថាប័នជាតិ និងប្រព័ន្ធអភិបាលកិច្ច ដើម្បីធានាបានប្រសិទ្ធភាព គណនេយ្យភាព តម្លាភាព នឹងធានាបានសមធម៌សង្គម ដែលមានបរិយាប័ន្ន ផ្តល់ឱកាសស្មើគ្នា និងប្រកបដោយយុត្តិធម៌។ ក្នុងន័យនេះ ចំណូលក្នុងស្រុករបស់កម្ពុជានឹងក្លាយជាភ្នាស់យ៉ាងសំខាន់ក្នុង ការទ្រទ្រង់កំណើនសេដ្ឋកិច្ច ការផ្តល់ការងារជូនប្រជាពលរដ្ឋ តាមរយៈការបែងចែកឡើងវិញនូវផលទុនជាតិក្នុងក្របខ័ណ្ឌនៃប្រព័ន្ធថវិការជាតិដ៏សមស្របមួយ។ ម៉្យាងទៀត ការកៀរគរចំណូលឱ្យអស់សក្តានុពល គឺជាលក្ខខណ្ឌចាំបាច់ មិនអាចខ្វះបាន សម្រាប់ពង្រឹងភាពជាម្ចាស់លើការអភិវឌ្ឍន៍ប្រទេស និងបំពេញឱ្យបានគ្រប់គ្រាន់ទៅនឹងតម្រូវការ នៃការចំណាយសាធារណៈចាំបាច់នានា ដើម្បីចូលរួមវិភាគទានដល់ការសម្រេចឱ្យបាននូវចក្ខុវិស័យខាងលើ។

ខ.បេសកកម្ម



រូបភាពទី ៣ ៖អគ្គនាយកដ្ឋានពន្ធដារគ្រងដាក់ឱ្យដំណើរការកម្មវិធីរដ្ឋបាលអេឡិចត្រូនិច

អគ្គនាយកដ្ឋានពន្ធដារ បានផ្តល់នូវសេវាដែលមានគុណភាព ពង្រឹងការអនុវត្តច្បាប់ បទប្បញ្ញត្តិស្តីពីពន្ធដារប្រកបដោយភាពសុចរិត និងស្មើភាពចំពោះអ្នកជាប់ពន្ធទាំងអស់ ដើម្បីជម្រុញអនុលោមភាពដោយស្ម័គ្រចិត្តឈានទៅសម្រេចបាននូវការអភិវឌ្ឍន៍ និងលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជា។

អគ្គនាយកដ្ឋានពន្ធដារ បំពេញបេសកកម្ម និងធ្វើប្រតិបត្តិការរបស់ខ្លួនដោយប្រកាន់ខ្ជាប់នូវគុណតម្លៃ ដូចខាងក្រោម៖

- **ការអនុវត្ត** ៖ អនុវត្តវិធាននៃច្បាប់ គាំទ្រប្រជាពលរដ្ឋដែលប្រព្រឹត្តត្រឹមត្រូវ តាមច្បាប់ និងតឹងរ៉ឹងចំពោះជនណាដែលមិនអនុលោមតាមច្បាប់
- **វិជ្ជាជីវៈ** ៖ ប្តេជ្ញាចិត្តប្រើវិជ្ជាជីវៈ និងជំនាញដើម្បីផ្តល់នូវសេវាដែលមានភាពសាមញ្ញ និងងាយស្រួល
- **ស័ក្តិសិទ្ធិភាព** ៖ ប្រើប្រាស់ធនធានឱ្យទាន់ពេលវេលា និងមានប្រសិទ្ធភាព
- **សុចរិតភាព** ៖ ផ្តល់សេវាឱ្យប្រជាពលរដ្ឋដោយស្មើភាព និងតម្លាភាព
- **គារវភាព** ៖ ផ្តល់សេវាឱ្យប្រជាពលរដ្ឋប្រកបដោយភាពថ្លៃថ្នូរ និងការគោរព
- **ភាពបត់បែន** ៖ ឆ្លើយតបយ៉ាងសកម្មទៅនឹងបញ្ហាប្រឈម និងទាញយកប្រយោជន៍ពីគ្រប់ឱកាសដែលមាន។

គ. គោលដៅ



រូបភាពទី ៤ ៖ មន្ត្រីជំនាញនៃអគ្គនាយកដ្ឋានពន្ធដារពន្យល់ពីវិធានការទូទៅស្តីពីចំណាយ

យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមមាន គោលបំណងពង្រឹងរដ្ឋបាលសារពើពន្ធ មិនមែនសារពើពន្ធ លើកកម្ពស់វប្បធម៌បង់ពន្ធ និងការគោរពច្បាប់ ដើម្បីពង្រឹងការប្រមូលចំណូលឱ្យមានប្រសិទ្ធភាព ឆ្លើយតបទៅនឹងតម្រូវការសេដ្ឋកិច្ចទីផ្សារដែលកំពុងលូតលាស់ នឹងការកើនឡើងនៃចំនួនអ្នកបង់ពន្ធ ក៏ដូចជាភាពស្មុគស្មាញនៃសកម្មភាព សេដ្ឋកិច្ចក្នុងសម័យទំនើប ព្រមទាំងផ្តល់ភាពងាយស្រួលដល់ការគ្រប់គ្រងប្រកបដោយប្រសិទ្ធ ភាពនូវការផ្តល់សេវាកម្មជូនអ្នកបង់ពន្ធ រួមចំណែកកែលម្អបរិយាកាសវិនិយោគ និងការអភិវឌ្ឍន៍វិស័យឯកជន នឹងធានា បាននូវសមធម៌ និងយុត្តិធម៌សម្រាប់ពលរដ្ឋទាំងអស់។

ដើម្បីសម្រេចគោលបំណងខាងលើ យុទ្ធសាស្ត្រកៀរគរចំណូលរយៈ ពេលមធ្យមមានគោលដៅដូចតទៅ ៖

១-ប្រមូលចំណូលចរន្តសរុបឱ្យកើនបានយ៉ាងតិចបំផុត ០,៥ ពិន្ទុ ភាគរយបន្ថែមលើផលធៀបរវាងចំណូលចរន្ត និងផលិតផលក្នុងស្រុកសរុបជារៀងរាល់ឆ្នាំ ដោយត្រូវកើនពី ១៥,១៨% នៅឆ្នាំ២០១៤ ដល់ ១៧, ៣៥% នៅឆ្នាំ២០១៨ ។

២-ឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍ដើម្បីរក្សាកំណើនសេដ្ឋកិច្ចខ្ពស់និងសម្រេចគោលដៅអភិវឌ្ឍន៍ជាតិដែលស្របនឹង យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី ៣ និងដើម្បីត្រៀមខ្លួនក្លាយជាប្រទេសចំណូលមធ្យម កម្រិតខ្ពស់នាពេលខាងមុខ។

### ៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ច របស់អគ្គនាយកដ្ឋានពន្ធដារ

#### ក. រចនាសម្ព័ន្ធនៃការប្រមូលពន្ធ




រូបភាពទី ៥ ៖ រចនាសម្ព័ន្ធស្ថាប័ន

❖ **រចនាសម្ព័ន្ធនៃការគ្រប់គ្រង**

- **ឯកឧត្តម គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ
- **ឯកឧត្តម អ៊ុំ សីហា** អគ្គនាយករង
- **ឯកឧត្តម ជាប ដារ៉ុធ** អគ្គនាយករង
- **ឯកឧត្តម ម៉ិញ បានកុសល** អគ្គនាយករង
- **ឯកឧត្តម កែន សម្បត្តិ** អគ្គនាយករង
- **ឯកឧត្តម ហេង សុខណាង** អគ្គនាយករង
- **លោកជំទាវ ប៊ុន នារី** អគ្គនាយករង
- **ឯកឧត្តម រ័ត្ន មុនី** អគ្គនាយករង
- **លោក លឹម ជឺលុច** អគ្គនាយករង
- **ឯកឧត្តម លឹម ហ៊ុយជីវ** អគ្គនាយករង

❖ **នាយកដ្ឋាននៃអគ្គនាយកដ្ឋានពន្ធដារ**

- នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
- នាយកដ្ឋានហិរញ្ញវត្ថុ និងបុគ្គលិក
- នាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ
- នាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ
- នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
- នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ
- នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
- នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម
- នាយកដ្ឋានសវនកម្មសហគ្រាស
- សាលាជាតិពន្ធដារ
- ទីចាត់ការពន្ធដាររាជធានីភ្នំពេញ

❖ **សាខាពន្ធដារខណ្ឌ-ខេត្ត**

- សាខាពន្ធដារខណ្ឌ ឫស្សីកែវ
- សាខាពន្ធដារខណ្ឌ ដូនពេញ
- សាខាពន្ធដារខណ្ឌ ៧មករា
- សាខាពន្ធដារខណ្ឌ មានជ័យ
- សាខាពន្ធដារខណ្ឌ ចំការមន
- សាខាពន្ធដារខណ្ឌ ទួលគោក
- សាខាពន្ធដារខណ្ឌ ដង្កោ
- សាខាពន្ធដារខណ្ឌ សែនសុខ

- សាខាពន្ធដារខណ្ឌ ពោធិសែនជ័យ
- សាខាពន្ធដារខេត្ត កណ្តាល
- សាខាពន្ធដារខេត្ត កំពង់ចាម
- សាខាពន្ធដារខេត្ត បាត់ដំបង
- សាខាពន្ធដារខេត្ត ព្រៃវែង
- សាខាពន្ធដារខេត្ត សៀមរាប
- សាខាពន្ធដារខេត្ត កំពង់ធំ
- សាខាពន្ធដារខេត្ត តាកែវ
- សាខាពន្ធដារខេត្ត ស្វាយរៀង
- សាខាពន្ធដារខេត្ត ពោធិ៍សាត់
- សាខាពន្ធដារខេត្ត កំពង់ឆ្នាំង
- សាខាពន្ធដារខេត្ត កំពង់ស្ពឺ
- សាខាពន្ធដារខេត្ត កំពត
- សាខាពន្ធដារខេត្ត ព្រះសីហនុ
- សាខាពន្ធដារខេត្ត កោះកុង
- សាខាពន្ធដារខេត្ត ព្រះវិហារ
- សាខាពន្ធដារខេត្ត ក្រចេះ
- សាខាពន្ធដារខេត្ត រតនគិរី
- សាខាពន្ធដារខេត្ត មណ្ឌលគិរី
- សាខាពន្ធដារខេត្ត បន្ទាយមានជ័យ
- សាខាពន្ធដារខេត្ត ស្ទឹងត្រែង
- សាខាពន្ធដារខេត្ត កែប
- សាខាពន្ធដារខេត្ត ប៉ៃលិន
- សាខាពន្ធដារខេត្ត ឧត្តរមានជ័យ
- សាខាពន្ធដារខេត្ត ត្បូងឃ្មុំ ។

### ខ. តួនាទីនៃការប្រមូលពន្ធ

នៅក្នុងគោលការណ៍ប្រមូលពន្ធលើអចលនទ្រព្យ នៃព្រះរាជាណាចក្រកម្ពុជាការប្រមូលពន្ធនានាពាក់ព័ន្ធនឹងអចលនទ្រព្យជាផ្នែកមួយ ដែលបានដើរតួនាទីយ៉ាងសំខាន់ដល់ការធានាតុល្យភាពនៃចំណូលជាតិ ។ ក្នុងនោះផងដែរ ពន្ធលើអចលនទ្រព្យជាប្រភេទពន្ធស្វ័យប្រកាសមួយ ដែលតម្រូវឱ្យអ្នកជាប់ពន្ធទាំងអស់(កម្មសិទ្ធិករ អ្នកកាន់កាប់ អ្នកទទួល ផលប្រយោជន៍ចុងក្រោយ)យើងត្រូវយកមកចុះបញ្ជីពន្ធលើអចលនទ្រព្យ ធ្វើបច្ចុប្បន្នភាពព័ត៌មានអចលនទ្រព្យនិងដាក់លិខិតប្រកាសបង់ពន្ធនៅអគ្គនាយកដ្ឋានពន្ធដារ ឬសាខាពន្ធដារខណ្ឌ-ខេត្តដែលអចលនទ្រព្យស្ថិតនៅ ។

ពន្ធលើអចលនទ្រព្យគឺជាប្រភេទពន្ធប្រចាំឆ្នាំមួយ ដែលតម្រូវឱ្យប្រមូលទៅតែចំពោះអចលនទ្រព្យណាដែលមានតម្លៃលើសពី ១០០.០០០.០០០(មួយរយលានរៀល) និងមានទីតាំងស្ថិតនៅក្នុង ភូមិសាស្ត្ររដ្ឋបាលរាជធានី និងរដ្ឋបាលក្រុងនៃខេត្តនានា ក្នុងព្រះរាជាណាចក្រកម្ពុជា។ពន្ធប្រភេទនេះត្រូវប្រមូលដោយរដ្ឋបាលសារពើពន្ធ ក្នុងគោលបំណងដើម្បីជាប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ (រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់) សម្រាប់ការអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួន ។




**រូបភាពទី ៦ ៖ ដំណើរការនៃការប្រមូលពន្ធ**

### គ. ភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ




**រូបភាពទី ៧ ៖ ភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ**

អគ្គនាយកដ្ឋានពន្ធដារមានភារកិច្ចជាអាទិ៍ដូចខាងក្រោម ៖

- រៀបចំគោលនយោបាយសារពើពន្ធ និងការប្រមូលពន្ធគ្រប់ប្រភេទបង់ចូលថវិការជាតិ
- រៀបចំសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋាននានាស្តីពីពន្ធដារ កំណត់បញ្ជីឯកសារចាំបាច់នានា និងលិខិតយុត្តិការដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវកាន់កាប់រក្សាទុក នឹងផ្តល់ជូនរដ្ឋាភិបាលសារពើពន្ធ
- កំណត់មូលដ្ឋានគិតពន្ធលើអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកដោយផ្អែកលើការសង្កេត និងផ្ដុំព័ត៌មាន
- គណនា និងប្រមូលប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងចំណូលផ្សេងៗ
- កសាងកម្មវិធី និងអនុវត្តការងារសេវនកម្មចំពោះអ្នកជាប់ពន្ធ
- ទទួលបន្ទុកសហប្រតិបត្តិការអន្តរជាតិក្នុងផ្នែកពន្ធដារ
- អនុវត្តទោសទណ្ឌតាមច្បាប់ចំពោះអ្នកជាប់ពន្ធ និងភ្នាក់ងារកាត់ទុក ដែលល្មើសបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- ចូលរួមរៀបចំគម្រោងថវិការជាតិប្រចាំឆ្នាំ ដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ។

## ៣.២ នីតិវិធីក្នុងការប្រមូលពន្ធលើអចលនទ្រព្យរបស់អគ្គនាយកដ្ឋានពន្ធដារ

### ៣.២.១ មូលដ្ឋាននិងនីតិវិធីនៃការប្រមូលពន្ធលើអចលនទ្រព្យ

មូលដ្ឋាននៃការប្រមូលពន្ធលើអចលនទ្រព្យ របស់អគ្គនាយកដ្ឋានពន្ធដារ ដែលជាប្រភេទពន្ធលើអចលនទ្រព្យដែលរដ្ឋាភិបាល បានកំណត់នូវកម្មវត្ថុដោយផ្ទាល់នៃពន្ធលើបុគ្គល និងពន្ធលើទ្រព្យសម្បត្តិ ។ ទ្រព្យសម្បត្តិដែលជាប់ពន្ធរួមមាន ចលនទ្រព្យនិងអចលនទ្រព្យ។ រីឯបុគ្គលជាប់ពន្ធរួមមានរូបវន្តបុគ្គលនិងនីតិបុគ្គលដែលមានស្ថានភាពគតិយុត្តជា ពាណិជ្ជករ អាជីវកម្ម ឬកម្មសិទ្ធិករជាដើម ។

នីតិវិធីក្នុងការប្រមូលពន្ធលើអចលនទ្រព្យនៅប្រទេសកម្ពុជាត្រូវបានបែងចែកជា ៤ ប្រភេទរួមមានដូចជា ៖

**ក.ពន្ធលើអចលនវត្ថុ** សំដៅលើពន្ធ ដី ផ្ទះ អគារ ឬសំណង់ផ្សេងៗ ដែលសង់ជាប់ដី ដោយស្ថិតក្នុងទីតាំងជាក់លាក់ណាមួយ ក្នុងតំបន់ទីក្រុង។ ពន្ធលើអចលនវត្ថុចាប់ផ្តើមអនុវត្តន៍តាំងពីឆ្នាំ២០១១ ជាមួយនឹងអត្រាពន្ធ០.១ភាគរយ សម្រាប់អចលនទ្រព្យ ដែលមានតម្លៃលើសពី១០០លានរៀល ឬស្មើនឹង ២៥,០០០ ដុល្លារអាមេរិក។

**ខ.ពន្ធលើដីទំនេរ ឬដីធ្លីមិនបានប្រើប្រាស់** ត្រូវបានដាក់ឱ្យប្រើប្រាស់ ក្នុងឆ្នាំ១៩៩៥ នឹងត្រូវបានកំណត់ លើដីប្រភេទលំនៅដ្ឋាន ដែល គ្មាន សំណង់ និង ដី ដែលមាន សំណង់តែត្រូវបាន បោះបង់ ដែលស្ថិតនៅក្នុង ទីក្រុង នានា និង ក្នុង តំបន់ទាំងឡាយណា ដែល កំណត់ដោយ គណៈកម្មការ វាយតម្លៃ ដី មិនបានប្រើប្រាស់។ ពន្ធនេះត្រូវបានកំណត់ក្នុងអត្រា២ភាគរយ ទៅតាមតម្លៃទីផ្សារនៃដីក្នុងមួយម៉ែត្រការ៉េ។

**គ.ពន្ធប្រថាប់ត្រា (ពន្ធលើការផ្ទេរអចលនទ្រព្យ )** ត្រូវបានកំណត់ក្នុងអត្រា៤% ដោយគណៈកម្មការវាយតម្លៃអចលនទ្រព្យ ផ្អែកតាមតម្លៃទីផ្សារទិញលក់ និងផ្ទេរកម្មសិទ្ធនៃអចលនទ្រព្យនោះ។ ជាទូទៅពន្ធនេះគឺជាកាតព្វកិច្ចរបស់អ្នកទិញ ប៉ុន្តែអាចផ្លាស់ប្តូរបានអាស្រ័យលើកិច្ចសន្យាទិញលក់ ហើយអ្នកជាប់ពន្ធត្រូវបង់ក្នុងអំឡុងពេល ៣ខែក្រោយពីការផ្ទេរកម្មសិទ្ធិ ។

**ឃ.ពន្ធលើឈ្នួលអចលនទ្រព្យ ឬពន្ធលើការជួល** ត្រូវបានអនុវត្តន៍លើប្រជាជនខ្មែរ និងជនបរទេសដែលជាម្ចាស់នៃអចលនទ្រព្យជាក់ជួល ប៉ុន្តែត្រូវបានកំណត់អត្រាពន្ធកាត់ទុកផ្សេងគ្នា។ ចំពោះប្រជាជនខ្មែរត្រូវបង់ពន្ធកាត់ទុកចំនួន១០% ចំណែកជនបរទេសត្រូវបង់ពន្ធ ១៤% ពីប្រាក់ចំណូល ដែលពួកគេទទួលបានពីការជួល អចលនទ្រព្យជារៀងរាល់ឆ្នាំ។

### ៣.២.២ ការគ្រប់គ្រងការប្រមូលពន្ធលើអចលនទ្រព្យ




រូបភាពទី ៨ ៖ ចំណូលពន្ធពីប្រតិបត្តិការពាណិជ្ជកម្ម

អនុលោមតាមផ្នែកទី២ ស្តីពីពន្ធលើអចលនទ្រព្យនៃច្បាប់សារពើពន្ធ ដែលបានស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៩ និងប្រកាសលេង ៤៩៣ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យក្រសួងសេដ្ឋកិច្ច និងហិញ្ញវត្ថុសូមធ្វើការណែនាំអំពីវិធានការ និងនីតិវិធីនៃការអនុវត្តប្រមូលពន្ធលើអចលនទ្រព្យដូចខាងក្រោម ៖

**I. អចលនទ្រព្យដែលត្រូវជាប់ពន្ធ ៖**

អចលនទ្រព្យដែលស្ថិតនៅក្នុងភូមិសាស្ត្ររដ្ឋបាលរាជធានី និងខេត្ត នៃព្រះរាជាណាចក្រកម្ពុជា ត្រូវជាប់ពន្ធលើអចលនទ្រព្យ។ពន្ធនេះត្រូវប្រមូលចំពោះអចលនទ្រព្យដែលមានតម្លៃលើសពី១០០.០០០.០០០ ( មួយរយលាន ) រៀល ។ក្នុងដំណាក់កាលដំបូងពន្ធលើអចលនទ្រព្យត្រូវ បានអនុវត្តន៍ចំពោះទៅតែនឹងអចលនទ្រព្យ ដែលស្ថិតក្នុងភូមិសាស្ត្ររដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ និងរដ្ឋបាលក្រុងនៃខេត្តនានាដែលនៅក្នុងព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ ។

អ្នកជាប់ពន្ធ ( ម្ចាស់អចលនទ្រព្យ ) ដែលមានអចលនទ្រព្យមានតម្លៃលើសពី ១០០.០០០.០០០ ( មួយរយលាន ) រៀល ត្រូវមានកាតព្វកិច្ចចុះបញ្ជី ដាក់លិខិតប្រកាស និងបង់ពន្ធនៅរដ្ឋបាលសារពើពន្ធ ក្នុងភូមិសាស្ត្រដែលអចលនទ្រព្យនោះស្ថិតនៅ យ៉ាងយឺតបំផុតត្រឹមនៅថ្ងៃទី៣០ ខែកញ្ញានៃឆ្នាំជាប់ពន្ធនីមួយៗ។

ពន្ធលើអចលនទ្រព្យជាប្រភេទពន្ធស្វ័យ ប្រកាសក្នុងករណីដែលមានឧបសគ្គផ្សេងៗទៀត ដោយម្ចាស់អចលនទ្រព្យ ត្រូវបំពេញព័ត៌មានអចលនទ្រព្យពាក្យស្នើសុំចុះបញ្ជីពន្ធលើអចលនទ្រព្យ លិខិតប្រកាសបង់ពន្ធលើអចលនទ្រព្យ និងគណនា ព្រមទាំងបង់ប្រាក់ពន្ធដោយខ្លួនឯង ។

ពន្ធលើអចលនទ្រព្យនេះត្រូវប្រមូលដោយ រដ្ឋបាលសារពើពន្ធ និងបង់ចូលក្នុងគណនីទោលរបស់នៃរតនាគារជាតិដើម្បីជាប្រយោជន៍ដល់ថវិការរដ្ឋបាលក្រោមជាតិ( រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ/ឃុំ/សង្កាត់ ) សម្រាប់ការអភិវឌ្ឍន៍មូលដ្ឋាន ។

**II. អចលនទ្រព្យដែលត្រូវបានលើកលែងពន្ធ ៖**

អចលនទ្រព្យដែលត្រូវបានលើកលែងពន្ធ មានដូចជា ៖

១. អចលនទ្រព្យដែលជាដីធ្លីកសិកម្ម « ដីធ្លីកសិកម្ម » គឺជាដីស្ថិតក្នុងតំបន់ ឬប្រភេទដីកសិកម្មដែលកំពុងតែបង្កបង្កើតផល មានជាអាទិ៍ ដីស្រែ ដីចំការ ដំណាំកសិឧស្សាហ៍កម្ម ដីកសិដ្ឋានចិញ្ចឹមសត្វ វារីវប្បកម្ម ដីស្រែអំបិល ។

ក្នុងករណី អចលនទ្រព្យ ឬចំណែកណាមួយនៃអចលនទ្រព្យដែលស្ថិតនៅក្រៅតំបន់ ឬ ក៏ប្រភេទដីកសិកម្ម ( តំបន់លំនៅដ្ឋាន តំបន់ពាណិជ្ជកម្ម តំបន់ឧស្សាហ៍កម្ម ) ដែលកំពុងបង្កបង្កើនផលកសិកម្មក្រោមរូបភាពដូចខាងក្រោម ត្រូវបានលើកលែងពន្ធលើអចលនទ្រព្យ ៖

- ចិញ្ចឹមសត្វ ត្រូវមានលិខិតអនុញ្ញាតពីមន្ទីរកសិកម្ម
- វារីវប្បកម្ម ត្រូវមានលិខិតអនុញ្ញាតពីរដ្ឋបាលជលផល
- ក្រៅពីការចិញ្ចឹមសត្វ និងវារីវប្បកម្ម ត្រូវមានលិខិតបញ្ជាក់ពីខណ្ឌ/ស្រុក/ក្រុង

**ឧទាហរណ៍១ ៖** លោក « សុខ » មានដីមួយកន្លែងស្ថិតក្នុងតំបន់ ឬប្រភេទដីលំនៅដ្ឋាន ដែលមានទំហំ២.០០០ ម៉ែត្រក្រឡា ។ ដីនោះចំនួន ១.០០០ ម៉ែត្រក្រឡា កំពុងធ្វើស្រែដោយមានលិខិតបញ្ជាក់ពីខណ្ឌ/ស្រុក/ក្រុង ដីចំនួន ២០០ ម៉ែត្រក្រឡា សាងសង់លំនៅដ្ឋាន និងដីចំនួន ៨០០ ម៉ែត្រក្រឡា កំពុងចិញ្ចឹមត្រី ដោយមានការអនុញ្ញាតពីរដ្ឋបាលជលផល ។

ក្នុងករណីនេះ ដីចំនួន ២០០ ម៉ែត្រក្រឡាសាងសង់ធ្វើលំនៅដ្ឋាន និងសំណង់ ត្រូវជាប់ពន្ធលើអចលនទ្រព្យ ។ ចំពោះដីចំនួន ១.០០០ ម៉ែត្រក្រឡា កំពុងធ្វើស្រែ និងដីចំនួន ៨០០ ម៉ែត្រក្រឡាកំពុងចិញ្ចឹមត្រីនិងសំណង់ដែលបម្រើផ្ទាល់ដល់ការងារចិញ្ចឹមត្រី ត្រូវបានលើកលែងពន្ធលើអចលនទ្រព្យ ។

២. អចលនទ្រព្យដែលជាកម្មសិទ្ធិរបស់រដ្ឋកិបាល ឬស្ថាប័នរដ្ឋាភិបាល ដូចជា សាលារៀន មន្ទីរពេទ្យ ក្រសួងមន្ទីរស្ថាប័ន...ដែលបានចុះក្នុងបញ្ជីសារពើភណ្ឌជាទ្រព្យសម្បត្តិរបស់រដ្ឋ ។ ក្នុងករណីអចលនទ្រព្យដែលបានកត់ត្រាជាទ្រព្យសកម្មធ្វើអាជីវកម្មរបស់សហគ្រាសសាធារណៈ ឬក្រុមហ៊ុនចម្រុះរដ្ឋ អចលនទ្រព្យនោះមិនត្រូវបានលើកលែងពន្ធលើអចលនទ្រព្យឡើយ ។ ចំពោះដីរដ្ឋ ដែលរាជរដ្ឋាភិបាលបានជួលឱ្យឯកជនសាងសង់សំណង់សម្រាប់ធ្វើអាជីវកម្មដី ត្រូវបានលើកលែងពន្ធលើអចលនទ្រព្យ ប៉ុន្តែសំណង់ត្រូវជាប់ពន្ធ ។

**ឧទាហរណ៍ ៖** លោក « សៅ » បានជួលដីពីរដ្ឋរយៈពេល ៥០ ឆ្នាំ ហើយបានសាងសង់សណ្ឋានគារមួយដើម្បីធ្វើអាជីវកម្ម ។ ក្នុងករណីនេះ ដីដែលគាត់បានជួលពីរដ្ឋ ត្រូវបានលើកលែងពន្ធលើអចលនទ្រព្យ ។

៣. អចលនទ្រព្យដែលជាកម្មសិទ្ធិរបស់សហគមន៍ ឬបុគ្គលណាមួយ ដែល ៖

- ត្រូវបានរៀបចំឡើង និងដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនា និងសប្បុរសធម៌។
- គ្មានចំណែកណាមួយនៃអចលនទ្រព្យ ឬប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាប្រយោជន៍ឯកជន ។

- **ការលើកឡើងពន្ធលើអចលនទ្រព្យនេះមិនរាប់បញ្ចូលទេ ចំពោះ ៖**

- អចលនទ្រព្យដែលត្រូវបានជួល ឬផ្តល់ឱ្យបណ្តោះអាសន្ន សម្រាប់គោលដៅសុទ្ធសាធខាងសាសនា និងសប្បុរសធម៌។

- អចលនទ្រព្យជាកម្មសិទ្ធិរបស់អង្គការសាសនា ឬអង្គការសប្បុរសធម៌ ដែលបានឱ្យជួលឬផ្តល់ជាបណ្តោះអាសន្នទៅសមាគមន៍ ឬបុគ្គលណាមួយ ដែលប្រើប្រាស់អចលនទ្រព្យនោះក្រៅពីគោលដៅសាសនា និងសប្បុរសធម៌ ។

៤. អចលនទ្រព្យជាកម្មសិទ្ធិរបស់ ៖

- បេសកម្មការទូត ឬកុងស៊ុលបរទេស
- អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រត្តិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានាដែលទទួលស្គាល់ដោយរាជរដ្ឋាភិបាល ។

- **ការលើកលែងពន្ធនេះមិនរាប់បញ្ចូលទេចំពោះ ៖**

- អចលនទ្រព្យជាកម្មសិទ្ធិរបស់ឯកជន ហើយបានជួលឱ្យទៅការទូត កុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេលទេសរបស់រដ្ឋាភិបាលនានា ដែលបានជួលឱ្យទៅអតិថិជន ។

៥. អចលនទ្រព្យដែលជារបស់ហេដ្ឋារចនាសម្ព័ន្ធ រួមមាន ផ្លូវ ស្ពាន ប្រព័ន្ធផលិតទឹកស្អាត ឬផលិតអគ្គសនីព្រលានយន្តហោះ កំពង់ផែ សកថានៅយអយស្ម័យយាន រួមបញ្ចូលទាំងអគារ និងការិយាល័យដែលបម្រើផ្ទាល់ដល់សកម្មភាពនៃហេដ្ឋារចនាសម្ព័ន្ធទាំងនេះ ។

**ឧទាហរណ៍ ៖** លោក « សាន » បានធ្វើរោងចក្រអគ្គិសនីនៅលើដីមួយកន្លែង និងមានអគារមួយខ្នងនៅក្នុងបរិវេណដីនោះសម្រាប់បម្រើដល់ការងារផលិតកម្មអគ្គិសនី ។ រោងចក្រអគ្គិសនីខាងលើ ក៏មានការិយាល័យមួយចំនួនដែលស្ថិតនៅក្រៅបរិវេណដីខាងលើ ។

ក្នុងករណីនេះ ដី និងអគារសម្រាប់បម្រើដល់ការងារផលិតកម្មអគ្គិសនី ពុំជាប់ពន្ធលើអចលនទ្រព្យឡើយហើយការិយាល័យដែលស្ថិតនៅក្រៅបរិវេណដីខាងលើ ក៏ពុំត្រូវជាប់ពន្ធលើអចលនទ្រព្យ ដែរ ។

៦. ផ្ទះ អគារ និងសំណង់ផ្សេងៗ ដែលសាងសង់លើដីធ្លីកសិកម្មដែលបម្រើផ្ទាល់ និងជាអចិន្ត្រៃយ៍ដល់សកម្មភាពកសិកម្ម។

៧. អចលនទ្រព្យដែលទទួលរងនូវការខូតខាតធ្ងន់ធ្ងរដោយករណីប្រធានសក្តិ ដែលជាបាតុភូត ឬជាព្រឹត្តិការណ៍កើតឡើងដោយមិនដឹងជាមុន មិនអាចប៉ាន់ស្មានបានជាមុន និងមិនអាចជំនះបាន ដូចជា គ្រោះធម្មជាតិ ( ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយដី ) សង្គ្រាម កុប្បកម្ម អគ្គីភ័យ គ្រោះមហន្តរាយជាយថាហេតុ ។

**ឧទាហរណ៍ ៖** លោក « សែ » មានដីមួយកន្លែងស្ថិតនៅតាមបណ្តោយមាត់ទន្លេមេគង្គនៅក្នុងក្រុងកំពង់ចាមនិងបានសង់ផ្ទះមួយខ្នងនៅក្នុងបរិវេណដីនោះសម្រាប់ស្នាក់នៅ ។ នៅខែសីហា និងកញ្ញានៃឆ្នាំនីមួយៗ ផ្ទះ និងដីរបស់គាត់នឹងទទួលរងនូវការលិចទឹករាល់ឆ្នាំ ។ក្នុងករណីនេះ ដីនិងផ្ទះរបស់គាត់ត្រូវជាប់ពន្ធលើអចលនទ្រព្យ ។

៨. ផ្ទះ អគារ ឬសំណង់ ដែលកំពុងត្រូវបានសាងសង់តិចជាង ៨០ ( ប៉ែតសិប ) ភាគរយ និងមិនទាន់បានប្រើប្រាស់ ត្រូវបានលើកលែងពន្ធលើអចលនទ្រព្យ បានន័យថា ផ្ទះ អគារ ឬសំណង់នោះត្រូវបានបំពេញលក្ខខណ្ឌពីរក្នុងពេលជាមួយគ្នាគឺ ទី១ កំពុងត្រូវបានសាងសង់តិចជាង ៨០ ( ប៉ែតសិប ) ភាគរយ និងទី២ មិនទាន់បានប្រើប្រាស់ ប៉ុន្តែដីត្រូវជាប់ពន្ធលើអចលនទ្រព្យ ។

ការប្រើប្រាស់ សំដៅដល់ការប្រើប្រាស់ផ្ទះ អគារ ឬសំណង់ សម្រាប់សកម្មភាពអាជីវកម្ម ឬស្នាក់នៅ ដោយមិនគិតថាការប្រើប្រាស់ ឬការស្នាក់នៅនោះ មានលក្ខណៈជាប់លាប់ ឬមួយដងមួយគ្រាឡើយ ។

៩. អចលនទ្រព្យដែលស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេស ដែលបម្រើផ្ទាល់ដល់សកម្មភាពផលិតកម្ម ត្រូវបានលើកលែងពន្ធលើអចលនទ្រព្យ ការលើកលែងពន្ធលើអចលនទ្រព្យនេះ មិនរាប់បញ្ចូលទេនូវសំណង់ដែលមិនបម្រើផ្ទាល់ដល់សកម្មភាពផលិតកម្ម ឬសេវាកម្មដែលជាកម្មវត្ថុនៃតំបន់សេដ្ឋកិច្ចពិសេសនោះ ដូចជា ផ្ទះល្វែង ផ្ទះវីឡា ភោជនីដ្ឋាន សណ្ឋាគារ កាស៊ីណូ កន្លែងលំហែកំសាន្តផ្សេងៗ ។

**ឧទាហរណ៍ ៖** លោក « សាន » បានទទួលសិទ្ធិគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសមួយ ក្នុងគោលបំណងដើម្បីសាងសង់រោងចក្រផលិតសំលៀកបំពាក់សម្រាប់នាំចេញ ។ ក្រោយមកលោក « សាន » បានសាងសង់ផ្ទះល្វែង ភូមិគ្រឹះ សណ្ឋាគារសម្រាប់លក់ ឬជួល ដែលជាសកម្មភាពមិនបម្រើផ្ទាល់ដល់ការផលិតសំលៀកបំពាក់នាំចេញ ដែលជាកម្មវត្ថុនៃតំបន់សេដ្ឋកិច្ចពិសេសនោះទេ ដូចនេះ សំណង់ទាំងនោះត្រូវជាប់ពន្ធលើអចលនទ្រព្យ ។

**III. ចំណែកនៃអចលនទ្រព្យដែលមិនត្រូវគិតបញ្ចូលជាមូលដ្ឋានពន្ធ ៖**

ចំណែកនៃផ្ទះ អគារ ឬសំណង់ផ្សេងៗ មានដូចខាងក្រោមនេះ មិនត្រូវគិតបញ្ចូលជាមូលដ្ឋានពន្ធលើអចលនទ្រព្យទេ ៖

១. ដំបូល ដែលគ្មានជញ្ជាំងជុំវិញ និងមិនធ្វើអាជីវកម្ម

២. សំយាបផ្ទះ ឬអគារ

៣. រានហាលផ្ទះ ឬអគារ

៤. ឡៅតឿ

៥. ផ្ទះបាយ និងបន្ទប់ទឹកក្រៅផ្ទះ ឬអគារ

៦. កន្លែងដាក់យានជំនិះមិនធ្វើអាជីវកម្ម នៅក្រៅផ្ទះ ឬអគារ

៧. កន្លែងហាត់កីឡាមិនធ្វើអាជីវកម្មនៅក្រៅផ្ទះ ឬអគារ

៨. កន្លែងដាក់ម៉ាស៊ីនភ្លើង ក្រៅផ្ទះ ឬអគារ

៩. អាងហែលទឹកមិនធ្វើអាជីវកម្មនៅក្រៅផ្ទះ ឬអគារ

១០. តូប ( Kiosk)

១១. របង និងខ្លោងទ្វារ

១២. ជណ្តើរប្រើប្រាស់រួមគ្នា

១៣. អាងស្តុកទឹក ឬប្រេងនៅក្រៅផ្ទះ ឬអគារ

១៤. អង់តែនទូរស័ព្ទ និងទូរទស្សន៍

១៥. ប៉ុស្ដិ៍យាម

១៦. ផ្លូវ ស្ពាន សួនច្បារ នៅក្រៅផ្ទះ ឬអគារ ។

### ៣.២.៣ របាយការណ៍ប្រមូលពន្ធលើអចលនទ្រព្យ



រូបភាពទី ៩ ៖ កិច្ចប្រជុំស្តីពី ការបូកសរុបលទ្ធផលប្រមូលចំណូលពន្ធប្រចាំខែ

យោងតាមរបាយការណ៍ ស្តីពីលទ្ធផលនៃការអនុវត្តថវិការឆមាសទី១ និងការវាយតម្លៃការអនុវត្តន៍ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបង្ហាញថា តាមការប៉ាន់ស្មានរហូតដល់បំណាច់ឆ្នាំ២០២៣ ចំណូលពន្ធដារនឹងសម្រេចបាននូវប្រមាណ១០៧.៥% នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ ដែលឆ្លុះបញ្ចាំងឱ្យឃើញពីប្រសិទ្ធភាពនៃកិច្ចខិតខំប្រឹងប្រែងក្នុងការអនុវត្តផែនការយុទ្ធសាស្រ្ត និងផែនការប្រតិបត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ។

ក្នុងរយៈពេល ៧ខែដើមឆ្នាំ២០២៣ ពន្ធ-អាករសរុប ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានមានចំនួន ៩ ៣៦៧,៤៤ ប៊ីលានរៀល (ប្រមាណជាង ២,៣១២,៩៥លានដុល្លារ) ស្មើរនឹង ៦៤.៧៦% នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣។ បើតាមព្រឹត្តិបត្រព័ត៌មានដដែល។

ព្រឹត្តិបត្រព័ត៌មានដដែល បានបន្តថា តែទោះជាយ៉ាងនេះក្តី បើពិនិត្យពីលទ្ធផលនៃការប្រមូលចំណូលពន្ធតាមប្រភេទពន្ធវិញ មានប្រភេទពន្ធមួយចំនួននៅតែមានបញ្ហាប្រឈម ជាក់ស្តែងក្នុងរយៈពេល ៧ខែ ដើមឆ្នាំ២០២៣ ការប្រមូលពន្ធលើអចលនទ្រព្យ របស់អគ្គនាយកដ្ឋានពន្ធដារ ក៏សម្រេចបាននូវចំនួន ៥៦,៩៩ប៊ីលានរៀល (ប្រមាណជា ១៤,២៥លានដុល្លារ) បើប្រៀបធៀបនឹងផែនការប្រចាំឆ្នាំ២០២៣ ទើបតែសម្រេចបាន ៣៦.៩៩% ប៉ុណ្ណោះ។

ដើម្បីជម្រុញការប្រមូលពន្ធលើអចលនទ្រព្យ និងចៀសវាងការផាកពិន័យលើម្ចាស់អចលនទ្រព្យដែលមិនបានបំពេញកាតព្វកិច្ចបង់ពន្ធនេះទាន់ពេលវេលាកាលពីថ្ងៃទី១១ខែសីហាឆ្នាំ២០២៣ អគ្គនាយកដ្ឋានពន្ធដារ បានចេញលិខិតជូនដំណឹងស្តីពីការតម្លើងលើកទី២ ការប្រកាស បង់ពន្ធលើអចលនទ្រព្យ និងឬពន្ធលើដីធ្លីមិនបានប្រើប្រាស់សម្រាប់ឆ្នាំ២០២៣ ក្នុងការក្រើនរំលឹកម្ចាស់អចលនទ្រព្យមួយចំនួនដែលនៅមិនទាន់បានបំពេញកាតព្វកិច្ចប្រកាសនិងបង់ប្រាក់ពន្ធ ឱ្យមករួសរាន់បង់ប្រាក់ពន្ធយ៉ាងយឺតបំផុតត្រឹម ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣ ជាកំណត់។ ចំពោះការខកខានមិនបានបំពេញកាតព្វកិច្ចសារពើពន្ធនេះ ម្ចាស់អចលនទ្រព្យនឹងត្រូវទទួលរងនូវទណ្ឌកម្មរដ្ឋបាលស្របតាមច្បាប់ ស្តីពីសារពើពន្ធ។

## ៣.៣ ផលប្រយោជន៍នៃការប្រមូលពន្ធលើអចលនទ្រព្យរបស់អគ្គនាយកដ្ឋានពន្ធដារ

### ៣.៣.១ កាតព្វកិច្ចនៃការបង់ពន្ធ




រូបភាពទី ១០ ៖ មូលហេតុនៃការបង់ពន្ធ

កាតព្វកិច្ចជាប់ពន្ធថ្មីៗជាច្រើនបែបនេះហើយទើបធ្វើឱ្យអ្នកខ្លះចោទជាសំនួរថា តើហេតុអ្វីបានជាគេត្រូវបង់ពន្ធ? តើពលរដ្ឋម្នាក់ៗទទួលបានផលប្រយោជន៍អ្វីខ្លះអំពីការបង់ពន្ធនេះ?

បើនិយាយតាមលក្ខណៈសង្គមសាស្ត្រ និងទស្សនវិជ្ជានយោបាយ យើងត្រូវបង់ពន្ធ ពីព្រោះ នេះគឺជាកាតព្វកិច្ចរបស់យើងគ្រប់គ្នា ក្នុងនាមជាពលរដ្ឋនៃប្រទេសមួយ។ កាតព្វកិច្ចបង់ពន្ធនេះ មានសម្រាប់ពលរដ្ឋគ្រប់ប្រទេសទាំងអស់ មិនថាតែនៅកម្ពុជា ឬនៅប្រទេសណាផ្សេងទៀតទេ។




រូបភាពទី ១១ ៖ លោកាតព្វកិច្ច និងបែបបទនៃការប្រកាសបង់ពន្ធ

តាមការពិត កាតព្វកិច្ចបង់ពន្ធនេះមានប្រវត្តិដ៏ចំណាស់រាប់ពាន់ឆ្នាំមកហើយ ពោលគឺ ចាប់តាំងពីការបង្កើតរដ្ឋដំបូងកាលពីប្រមាណជា ៦ពាន់ឆ្នាំមុនម្លេះ។បើនិយាយឱ្យចំទៅ ការបង់ពន្ធគឺជាមូលដ្ឋានគ្រឹះនៃការបង្កើតរដ្ឋ តាំងពីដំបូង គឺ រដ្ឋមានកាតព្វកិច្ចរក្សាសណ្តាប់ធ្នាប់ និងការពារសន្តិសុខរបស់ប្រជាជនព្រមទាំងធានាបាននូវសេវាសាធារណៈសម្រាប់សហគមន៍ ចំណែកពលរដ្ឋវិញមានកាតព្វកិច្ចបង់ពន្ធជូនរដ្ឋ។

និយាយពីការបង់ពន្ធ គេគួរធ្វើការបែងចែក រវាងការបង់អាករដូចជា ការបង់ថ្លៃទឹក ថ្លៃភ្លើង ឬថ្លៃប្រមូលសម្រាម ជាដើម ដែលជាការបង់ថ្លៃទៅលើសេវាកម្មណាមួយជាក់លាក់ និងការបង់ពន្ធទូទៅ ដូចជាការបង់ពន្ធទៅលើយានជំនិះ ពន្ធលើប្រាក់បៀវត្ស ពន្ធលើតម្លៃបន្ថែម ពន្ធលើប្រាក់ចំណេញរបស់ក្រុមហ៊ុន ឬ

ពន្ធលើអចលនទ្រព្យជាដើម ដែលមិនមែនជាការបង់ទៅលើសេវាណាមួយជាក់លាក់។ ប្រភេទពន្ធទូទៅនេះ ហើយ ដែលអាចឱ្យអ្នកបង់ពន្ធចោទជាសំណួរថា តើការបង់ពន្ធនេះទទួលបាននូវផលប្រយោជន៍អ្វីខ្លះ?

ការបង់ពន្ធគឺជាកាតព្វកិច្ចមួយដែលប្រជាពលរដ្ឋគ្រប់រូបត្រូវអនុវត្តន៍។ ប៉ុន្តែអ្នកមួយចំនួនប្រហែលមិនទាន់យល់ច្បាស់នៅឡើយទេថាហេតុអ្វីគាត់ត្រូវបង់ពន្ធ។

ដូច្នេះហើយទើបលើកយកប្រធានបទមួយនេះមកបកស្រាយប្រាប់បងប្អូនគ្រប់រូបអោយបានដឹងទាំងអស់គ្នា ថាហេតុអីបានយើងត្រូវបង់ពន្ធជូនរដ្ឋ។

មិនថាប្រទេសជឿនលឿន ឬប្រទេសកំពុងអភិវឌ្ឍដូចប្រទេសយើងនោះទេ ការបង់ពន្ធគឺមានដូចគ្នា គ្រាន់តែប្រភេទពន្ធនិងច្បាប់ស្តីពីការយកពន្ធអាចខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ។ តែដូចដែលដឹងស្រាប់ហើយថា ប្រទេសកម្ពុជាយើងគឺជាប្រទេសដែលកំពុងអភិវឌ្ឍ។ ដូចនេះ ពន្ធដែលបានប្រមូលពីពលរដ្ឋនឹងត្រូវបានយកទៅប្រើប្រាស់ក្នុងការសាងសង់នូវហេដ្ឋារចនាសម្ព័ន្ធនានា ដូចជាស្ពាន ថ្នល់ សាលារៀន មន្ទីរពេទ្យ ឬអគារសាធារណៈផ្សេងៗ សម្រាប់បម្រើប្រយោជន៍រួមដល់ប្រជាជន។ លើសពីនេះទៅទៀត ដោយរដ្ឋាភិបាលក៏មានកាតព្វកិច្ចក្នុងការរក្សាសណ្តាប់ធ្នាប់ ការពារសន្តិសុខសង្គម ជានានូវសេវាសាធារណៈទាំងឡាយសម្រាប់បម្រើ ប្រជាពលរដ្ឋក្នុងសហគមន៍ផងនោះ រដ្ឋក៏ត្រូវការធនធានហិរញ្ញវត្ថុដើម្បីដោះដូរជាមួយការផ្គត់ផ្គង់នូវសេវាកម្មទាំងនេះដោយអ្នកបម្រើសេវាកម្មសាធារណៈទាំងនោះដែរ ដូចជាគ្រូបង្រៀនបម្រើសេវាអប់រំ បុគ្គលិកមន្ទីរពេទ្យបម្រើសេវាសុខភាព និង ប៉ូលីសការពារសន្តិសុខជាដើម។ ហើយមួយផ្នែកនៃធនធានហិរញ្ញវត្ថុនោះនឹងត្រូវបានយកមកពីការបង់ពន្ធរបស់ប្រជាពលរដ្ឋនេះអែង។

ពន្ធដែលយើងបានបង់ជូនរដ្ឋអាចចាត់ទុកបានថាជាចំណូលរបស់រដ្ឋ ហើយការបង់ពន្ធនេះ ក៏ជាការចូលរួមចំណែកក្នុងថវិការជាតិ ដើម្បីឱ្យរដ្ឋមានលុយយកទៅធ្វើចំណាយ ដូចបានរៀបរាប់ខាងលើអញ្ចឹង។ម្យ៉ាងវិញទៀត ការបង្កើនចំណូលដល់រដ្ឋនេះដែរគឺជាគន្លឹះដ៏សំខាន់មួយ ដើម្បីរដ្ឋអាចកាត់បន្ថយជំនួយនិងកម្ចីពីបរទេសទៀតផង។

សរុបសេចក្តីមក ការបង់ពន្ធគឺជារឿងសំខាន់ដែល ប្រជាពលរដ្ឋត្រូវចូលរួមចំណែកនិងបំពេញកាតព្វកិច្ចជាពលរដ្ឋស្របច្បាប់ ដែលវានឹងឆ្លុះបញ្ចាំងពីសាមគ្គីភាព និងសមធម៌របស់ប្រជាពលរដ្ឋ រួមទាំងដើម្បីបានប្រយោជន៍ជាសមូហភាពផង។

### ៣.៣.២ ការប្រមូលពន្ធបានផ្តល់ផលប្រយោជន៍ដល់សង្គម និង សេដ្ឋកិច្ចជាតិ



រូបភាពទី ១២ ៖ ការរីកលូតលាស់ នៃការអភិវឌ្ឍន៍ សង្គម និង សេដ្ឋកិច្ចជាតិ

តាមការពិតការបង់ពន្ធ វាគឺជាការចូលរួមចំណែកមួយផ្នែកក្នុងថវិការជាតិដើម្បីឱ្យរដ្ឋមានលុយយកទៅចំណាយ ដោយមិនចាំបាច់បោះពុម្ពលុយ ដែលអាចបង្ករឱ្យមានបញ្ហាអតិផរណា។សម្រាប់កម្ពុជា ការបង្កើតចំណូលពីការបង់ពន្ធ គឺជាគន្លឹះដ៏សំខាន់មួយដើម្បីឈានទៅបញ្ឈប់ការពឹងផ្អែកលើជំនួយពីបរទេស។

សម្រាប់អ្នកបង់ពន្ធ ថ្វីត្បិតតែពន្ធនេះមិនមានកំណត់អំពីសេវាណាមួយជាថ្នូរមកវិញជាក់លាក់ក៏ពិតមែន ក៏ប៉ុន្តែគេអាចទទួលបានផលប្រយោជន៍ជាច្រើនដោយផ្ទាល់ ឬដោយប្រយោល ពីការបង់ពន្ធនេះ ពីព្រោះថា លុយដែលទទួលបានពីការបង់ពន្ធនេះនឹងត្រូវយកទៅចំណាយទៅលើការបើកប្រាក់បៀវត្សដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ដែលជាអ្នកទទួលនូវបន្ទុកផ្តល់សេវារដ្ឋបាល ការពារសន្តិសុខសណ្តាប់ធ្នាប់ និងការពារអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់ប្រទេស។



**រូបភាពទី ១៣ ៖ ទិដ្ឋភាពពីលើអាកាសរាជធានីភ្នំពេញ**

បើនិយាយពីការរស់នៅប្រចាំថ្ងៃវិញ ពលរដ្ឋម្នាក់ៗអាចទទួលបាននូវផលប្រយោជន៍ពីការបង់ពន្ធ ហើយពេលខ្លះទាំងមិនដឹងខ្លួន គឺតាមរយៈសេវាសាធារណៈឬហេដ្ឋារចនាសម្ព័ន្ធ ដែលគេប្រើប្រាស់ជារៀងរាល់ថ្ងៃ ដូចជា ស្ពាន ថ្នល់ សាលារៀន មន្ទីរពេទ្យ ។ល។ ដើម្បីជានានូវសេវាសាធារណៈទាំងអស់នេះ ដូចជា ការសាងសង់ ជួសជុលថែទាំ ស្ពាន ថ្នល់ អគារសាលារៀន និងមន្ទីរពេទ្យ ការបើកប្រាក់បៀវត្សដល់គ្រូបង្រៀន និងគ្រូពេទ្យ រដ្ឋត្រូវការចំណាយលុយ ហើយប្រភពចំណូលដ៏ធំបំផុតនៃថវិការបស់រដ្ឋ គឺបានមកពីបង់ពន្ធ។




រូបភាពទី ១៤ ៖ ទិដ្ឋភាពទីក្រុងភ្នំពេញនាពេលរាត្រី

អ្នកបង់ពន្ធខ្លះអាចនឹងរអ៊ូថា ផលប្រយោជន៍ដែលខ្លួនទទួលបានមានចំនួនតិច បើធៀបនឹងទំហំពន្ធដែលខ្លួនបានបង់។ ក៏ប៉ុន្តែ គេក៏មិនត្រូវភ្លេចដែរថា ការបង់ពន្ធមិនមែនធ្វើឡើងដោយសម្លឹងតែផលប្រយោជន៍ដែលនឹងត្រូវទទួលបានមកវិញនោះទេ។ គោលការណ៍ដ៏សំខាន់មួយ នៃការបង់ពន្ធ គឺ « សាមគ្គីភាព » និង « សមធម៌ »។ បន្ទុកបង់ពន្ធត្រូវតែសមាមាត្រទៅតាមលទ្ធភាពរបស់ពលរដ្ឋម្នាក់ៗ ក៏ប៉ុន្តែ សេវាសាធារណៈដែលកើតចេញពីការបង់ពន្ធនេះត្រូវបានជាប្រយោជន៍ដល់សមូហភាពទាំងមូល។ អ្នកដែលរកបានចំណូលបានច្រើនត្រូវបង់ច្រើន ហើយបើទោះបីជាផលប្រយោជន៍ដែលគេទទួលបានមកវិញ មានតិចជាងទំហំពន្ធដែលគេបានបង់ ក៏ប៉ុន្តែ គេបានចូលរួមចំណែកជួយដល់ពលរដ្ឋដែលខ្វះខាត។

ក៏ប៉ុន្តែ នេះគឺជាគោលការណ៍ រីឯនៅក្នុងការអនុវត្តន៍ ជាក់ស្តែងវិញ ជាពិសេស នៅក្នុងប្រទេសកម្ពុជា គេអាចយល់បានពីគំនិតរបស់ប្រជាជនរដ្ឋខ្លះ ដែលមិនសូវមានទឹកចិត្តបង់ពន្ធដោយសារតែគេគិតថា លុយដែលគេបង់ពន្ធនេះមិនប្រាកដថាបានចូលទៅក្នុងថវិការរដ្ឋទាំងអស់នោះទេ ដោយមួយផ្នែកអាចនឹងត្រូវជ្រុះចូលទៅក្នុងហោប៉ៅរបស់មន្ត្រីពុករលួយមួយចំនួន។ក្នុងពេលជាមួយគ្នា សេវាសាធារណៈ ដែលរដ្ឋត្រូវផ្តល់ជាតម្លៃតបស្នងដល់ការបង់ពន្ធ ក៏មិនត្រូវបានធានាឱ្យបានម៉ត់ចត់។ នៅសាលាការអប់រំមិនសូវមានគុណភាព នៅតាមមន្ទីរពេទ្យរដ្ឋភាគច្រើនបើអ្នកជម្ងឺគ្មានលុយឱ្យគ្រូពេទ្យ មិនអាចទទួលបានការព្យាបាលម៉ត់ចត់ទេ។ បើនិយាយពីសេវាកម្មពន្លត់អគ្គិភ័យ មន្ត្រីពន្លត់អគ្គិភ័យខ្លះ ទារយកលុយពីជនរងគ្រោះជាមុនសិន ទើបព្រមបាញ់ទឹកពន្លត់ភ្លើង។ចំពោះមន្ត្រីសាធារណៈវិញ ជាពិសេសមន្ត្រីជាន់ខ្ពស់ អ្នកមានខ្លះនាំគ្នាតាំងខ្លួនជាចៅហ្វាយ របស់ប្រជាពលរដ្ឋ ក្នុងពេលដែលពួកគេទទួលបានប្រាក់ខែពីថវិការរបស់រដ្ឋ ដែលមានន័យថាជាថវិការដែលបានមកពីការបង់ពន្ធរបស់ប្រជាជន៍។

# ជំពូកទី៤
# ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ

# ជំពូកទី ៤
# ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ

យោងតាមការសិក្សាស្រាវជ្រាវខាងលើ យើងសង្កេតឃើញថាការវិភាគគឺមានសារៈសំខាន់ក្នុងការវាយតម្លៃវែកពីដំណើរការនៃ ការប្រមូលពន្ធទៅលើប្រាក់ចំណូលរបស់ពន្ធលើអចលនទ្រព្យ ដើម្បីវែកញែកស្វែងរកចំណុចខ្លាំងនិងចំណុចខ្សោយបន្ទាប់មកយើងកែប្រែចំណុចខ្សោយឱ្យក្លាយទៅជា ចំណុចខ្លាំងដើម្បីជួយជម្រុញវិស័យពន្ធលើអចនទ្រព្យរបស់ប្រទេសយើងឱ្យកាន់តែរីកចម្រើន និង មានផលប្រយោជន៍កាន់តែជឿនលឿនទៅមុខទៀត។

## ៤.១ ការវិភាគលើចំណុចខ្លាំង

ការប្រពន្ធលើអចលនទ្រព្យមានគោលការណ៍ដកហូតពន្ធលើអចលនទ្រព្យដោយផ្អែកទៅ ការវិភាគចំណុចខ្លាំងមានដូចជា៖

- ការប្រមូលពន្ធរបស់ពន្ធដារបានគោរពតាមគោលការណ៍ និងការណែនាំរបស់ពន្ធដារសារពើពន្ធដែលមានដែនកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារយ៉ាងច្បាស់លាស់។
- ពន្ធដារនេះមាន ការគ្រប់គ្រងដំណើរការនៃការប្រមូលពន្ធលើប្រាក់ចំណូលប្រកបដោយប្រសិទ្ធភាពខ្ពស់ ដូចជាការគ្រប់គ្រងពន្ធលើអចលនទ្រព្យនិងលិខិតស្នាមបញ្ជាក់ពី ការបង់ពន្ធរបស់ម្ចាស់អាជីវកម្មបានច្បាស់លាស់។
- ការប្រមូលពន្ធនេះបាន ធ្វើសវនកម្មទៅលើក្រុមហ៊ុនមួយចំនួនដែល មិនបានអនុវត្តន៍តាមគោលការណ៍ច្បាស់លាស់ តាមច្បាប់ពន្ធដារនិងការគេចវេសការបង់ពន្ធ។
- ការប្រមូលពន្ធដើម្បីធ្វើការបណ្តុះបណ្តាលផ្ទៃក្នុង និងអគ្គនាយកដ្ឋានមានការប្រជុំផ្លាស់ប្តូរមួយលើកឬពីរលើកក្នុងមួយខែដើម្បីជួយអោយប្រទេសមានការរីកចម្រើននិងអភិវឌ្ឍជឿនលឿនបំផុត។
- មានការបញ្ជូនមន្ត្រីម្នាក់ៗ ចូលរួមសិក្ខាសាលាជាតិពន្ធដារ និងអគ្គនាយដ្ឋានពន្ធដារជាប់ជាប្រចាំដើម្បីជួយប្រជាពលរដ្ឋអោយមានចំណេះដឹង និងបទពិសោធន៍ថ្មីៗយកទៅពង្រឹងសម្ថភាព ក្នុងការផ្តល់សេវាដល់អ្នកជាប់ពន្ធនៅក្នុងសេដ្ឋកិច្ចជាតិ។
- ការប្រមូលពន្ធបានបិទផ្សាយជារៀងរាល់ថ្ងៃតាមរយៈព័ត៌មានផ្សេងៗដែរ បានទទួលពីក្រសួងសេដ្ឋកិច្ច និង អគ្គនាយកដ្ឋានពន្ធដារជាដំណឹងជូនដល់អ្នកជាប់ពន្ធទាំងអស់នៅក្នុងសង្គមជាតិ។

## ៤.២ ចំណុចខ្សោយនៃការប្រមូលពន្ធលើអចលនទ្រព្យ

ទន្ទឹមនឹងភាពវិជ្ជមានដែលកើតឡើងខាងលើ តាមរយៈការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំក៏មើលឃើញពីកង្វះខាតមួយចំនួន ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់បន្ថែម ដើម្បីឱ្យការប្រមូលពន្ធលើអចលនទ្រព្យកាន់តែប្រសើរឡើងដូចជា៖

- ការបណ្តុះបណ្តាលរបស់អគ្គនាយកដ្ឋានពន្ធដារ នៅមានកម្រិតនៅឡើយ ដែលធ្វើអោយអ្នកជាប់ពន្ធមួយចំនួនខ្វះការយល់ដឹងពីការបង់ពន្ធ។
- កង្វះមន្ត្រីពន្ធដារ ក្នុងការផ្តល់សេវាកម្មជូនដល់អ្នកជាប់ពន្ធ ជាពិសេសនៅពេលដែលមានចំនួនអ្នកមកប្រកាសពន្ធមានចំនួនច្រើន ពួកគាត់ត្រូវចំណាយពេលរងចាំយូរហើយ មន្ត្រីអគ្គនាយកដ្ឋានពន្ធដារបានទទួលលិខិតប្រកាសពីពួកគាត់រួចរាល់ ប៉ុន្តែមានភាពយឺតយ៉ាវក្នុងការបញ្ចូលទិន្នន័យបង់ពន្ធទៅក្នុងប្រព័ន្ធកត់ត្រាផ្ទៃក្នុងរបស់ពន្ធដារ ដែលធ្វើឱ្យពួកគាត់មិនអាចដឹងភ្លាមៗ ថាការគណនាពន្ធរបស់អ្នកជាប់ពន្ធត្រឹមត្រូវដែរឬទេ ហើយបើមានកំហុសឆ្គង ក្នុងការគណនាក្រោយពេលមន្ត្រីពន្ធដារ បានបញ្ចូនទិន្នន័យទៅក្នុងប្រព័ន្ធកត់ត្រាផ្ទៃក្នុង ហើយទើបដឹងហើយមន្ត្រីពន្ធដារធ្វើការជូនដំណឹងដល់អ្នកដែលជាប់ពន្ធមកធ្វើការកែតម្រូវការបង់ពន្ធជាហេតុធ្វើឱ្យ អ្នកជាប់ពន្ធត្រូវចំណាយពេលច្រើនថ្ងៃ ក្នុងការធ្វើដំណើរមកដាក់លិខិតប្រកាសពន្ធមួយឱ្យបានត្រឹមត្រូវ ។
- ដំណើរការនៃការបង់ប្រាក់ពន្ធនៅមានភាពយឺតយ៉ាវនៅឡើយ ដោយសារតែប្រតិបត្តិការនៃការបង់ប្រាក់ពន្ធនៅមានភាពមិនច្បាស់ពីបែបបទ និងវិធីសាស្ត្រនៃការគណនានៅឡើយ។
- អ្នកជាប់ពន្ធមិនទាន់យល់ច្បាស់ពីតួនាទី និងកាតព្វកិច្ចរបស់ខ្លួនក្នុងការបង់ប្រាក់ពន្ធជូនពន្ធដារ នៅឡើយ ដោយពួកគេគិតថាទឹកប្រាក់ដែលពួកគេបានបង់ជូនរដ្ឋ មិនបានផ្តល់ប្រយោជន៍ដល់ពួកគេនៅថ្ងៃអនាគតបាន។

# ជំពូកទី៥
# សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

# ជំពូកទី ៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

យោងតាមការសិក្សាស្រាវជ្រាវទៅលើប្រធានបទ ដំណើរការនៃការប្រមូលពន្ធលើអចលនទ្រព្យរបស់អគ្គយកដ្ឋានពន្ធដារកន្លងមកយើងបានសន្និដ្ឋានថា ដំណើរការនៃការប្រមូលពន្ធលើអចលនទ្រព្យ ជាការប្រមូលពន្ធមួយប្រភេទដែលទាក់ទងទៅនិង ពន្ធដារហើយមានអត្រាខ្ពស់ពីរមួយឆ្នាំទៅមួយឆ្នាំពីរបុគ្គលជាប់ពន្ធតាមរយៈ ផលរបបប្រចាំឆ្នាំដែលទទួលបានពីការប្រមូលពន្ធលើអចលនទ្រព្យផ្សេងៗ ក្នុងមួយឆ្នាំៗម្តង។ ម្យ៉ាងវិញទៀតការប្រមូលពន្ធលើអចលទ្រព្យក៏ជាចលករមួយ ជួយជម្រុញដល់ការអភិវឌ្ឍន៍ប្រទេសជាតិ និងបានជួយចូលរួមដោះស្រាយបញ្ហាសេដ្ឋកិច្ចផលដែរ។ តាមរយៈការយកទឹកប្រាក់ពន្ធដារ ដែលប្រមូលបានពីប្រជាពលរដ្ឋ រាជរដ្ឋាភិបាលបានយកទៅ សាងសង់សាលារៀន មន្ទីរពេទ្យ ផ្លូវថ្នល់ ប្រាក់បៀវត្សមន្ត្រីរាជការជនពិការភាព ហេដ្ឋារចនាសម្ព័ន្ធ និងផ្នែកផ្សេងៗជាច្រើនទៀត ដែលជាតម្រូវការរបស់សង្គមជាតិទាំងមូល។ ការប្រមូលពន្ធលើអចលនទ្រព្យបានជួយជម្រុញឱ្យ បុគ្គលជាប់ពន្ធលើអចលនទ្រព្យ មានកាតព្វកិច្ចចុះបញ្ជីនៅនាយកដ្ឋានគ្រប់គ្រងពន្ធធំ( គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សាខាក្រុមហ៊ុនបរទេស ឬ ក្រុមហ៊ុនពហុជាតិ និងសហគ្រាសដទៃទៀតដែលមានផលរបបជាប្រចាំឆ្នាំ ចាប់ពី ១,០០០លានរៀលឡើងទៅ) ឬ សាខាពន្ធដារខេត្ត/សាខាពន្ធដារខណ្ឌនៃរាជធានីភ្នំពេញ ដែលមានសហគ្រាសបានតាំងនៅត្រឹមរយៈពេល១៥ថ្ងៃបន្ទាប់ពីការចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច។លើសពីនេះទៅទៀត អគ្គនាយកពន្ធដារក៏បានចូលរួមចំណែកយ៉ាងសកម្មនឹងមានការយកចិត្តទុកដាក់បន្ថែមទៀតយ៉ាងម៉ត់ចត់ធ្វើឱ្យ ការប្រមូលពន្ធកើនឡើងខ្ពស់ ពីរមួយឆ្នាំទៅមួយឆ្នាំឆ្ពោះទៅរកភាពរីកចម្រើនជាលំដាប់គួរឱ្យកត់សម្គាល់ដើម្បីបញ្ជាក់ពីជំហយ៉ាងមុតមាំក្នុងប្រតិបត្តិការណ៍ទាំងអស់ចំពោះ ការប្រមូលពន្ធលើអចលនទ្រព្យរបស់អគ្គនាយកដ្ឋានពន្ធដារក្នុងរាជធានីភ្នំពេញ។ ពួកគាត់តែងតែកត់ត្រាចំណាំនៅក្នុងសៀវភៅបញ្ជីដោយរួមទាំងបញ្ជីសរសេរដៃ និងបញ្ចូលទិន្នន័យទៅក្នុងកុំព្យូទ័រថាតើអ្នកជាប់ប៉ុន្មានភាគរយ ដែលបានប្រកាសពន្ធលើអចលនទ្រព្យ ដែលស្ថិតនៅក្នុងប្រភេទពន្ធមួយចំនួនតែប៉ុណ្ណោះ ពួកគាត់បានបង្កើតឱ្យមានការធ្វើសវនកម្មទៅលើរបបស្វ័យប្រកាសដែលនឹងអាចធ្វើជាត្រីមាសឬប្រចាំឆ្នាំជាដើម។ ស្របជាមួយគ្នានេះដែរ ចំណុចមួយចំនួនក៏បានលាតត្រដាងពី ភាពខ្វះខាតនៅត្រង់ផ្នែកយុទ្ធស្រាស្ត្ររួមមាននូវ ការបង្ហាញអំពីទិសដៅនិងកម្មវិធីដាក់លាក់មួយចំនួន នៅការលើកតម្កើនដល់ការយល់ដឹងជាសកល នូវវប្បធម៌បង់ពន្ធ។ទិដ្ឋភាពនៃការិយាល័យពិគ្រោះយោបល់ តាមទូរស័ព្ទបានកាត់បន្ថយលទ្ធភាព ក្នុងការទទួលបាននូវព័ត៌មានលម្អិតដែលជាប់ទាក់ទងទៅនឹងការបង់ពន្ធ។ មិនតែប៉ុណ្ណោះគណៈគ្រប់គ្រងរបស់រដ្ឋបាល សារពើពន្ធមួយចំនួននិងសត្ថមភាពរបស់មន្ត្រីមិនទាន់ឆ្លើយតបទៅនឹងទំហំនៃ ការផ្តល់សេវាកម្មជូនដល់អ្នកជាប់ពន្ធឱ្យមានប្រសិទ្ធភាពនៅឡើយទេ។ រាល់បុគ្គលជាប់ពន្ធទាំងអស់ដែលស្ថិតនៅក្នុងខណ្ឌរាជធានីភ្នំពេញដែលមានអចលនទ្រព្យដូចជា ផ្ទះ ដី រថយន្ត ជាដើម តម្រូវឱ្យគោរពតាមបទបញ្ញត្តិនានា ដែលបានចែងនៅក្នុងច្បាប់សារពើពន្ធក្នុងព្រះរាជាណាចក្រកម្ពុជា។

សរុបសេចក្តីជារួមមក យើងបានសង្កេតឃើញថាទោះបីជាមានចំណុចខ្វះខាតមួយចំនួនពិតមែនក៏អគ្គយកដ្ឋានពន្ធដារបានបន្តខិតខំប្រឹងប្រែង នឹងកែលម្អរាល់ចំណុចខ្វះខាតទាំងអស់នោះ ដើម្បីឱ្យកាន់តែល្អ

ប្រសើរឡើងទ្វេរដងថែមទៀត។ ជាជាក់ស្តែងរាល់លទ្ធផលដែលទទួលបាននាពេលបច្ចុប្បន្នកន្លងមកនេះ ត្រូវបានបង្ហាញឱ្យឃើញថា អគ្គយកដ្ឋានពន្ធដារបានប្រមូលពន្ធ ដើម្បីចូលរួមចំណែកក្នុងការបង្កើនថវិការជូនជាតិឱ្យមានភាពកើនឡើងជាលំដាប់រៀងរាល់ឆ្នាំដែលសម្រេចបានទៅតាមផែនការដែលរដ្ឋាភិបាលដាក់ជូន។ មិនតែប៉ុណ្ណោះ ជាទូទៅការប្រមូលពន្ធដារតែងតែទទួលបានលើសផែនការដែលបានគ្រោងទុក នេះសុបបញ្ជាក់ថា អគ្គនាយកដ្ឋានពន្ធដារមិនបានបណ្តោយឬភ្លេចខ្លួនឡើយក្នុង ការបំពេញភារកិច្ចរបស់ខ្លួននោះទេ ដោយបច្ចុប្បន្ននេះអគ្គនាយដ្ឋានពន្ធដារបានខិតខំបណ្តុះបណ្តាល មន្ត្រីពន្ធដារឱ្យកាន់តែមានសម្ថភាព និងបន្តការកែលម្អច្បាប់ពន្ធដារឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ដើម្បីឱ្យដើរទាន់សភាពការណ៍សេដ្ឋកិច្ចដែលតែកំពុងរីកចម្រើនរីកសុះសាយយ៉ាងឆាប់រហ័ស។

## ៥.២ ការផ្តល់អនុសាសន៍

បន្ទាប់ពីបានវិភាគទៅលើចំណុចខ្លាំងនិងចំណុចខ្សោយ លើប្រធានបទ «ដំណើរការនៃការប្រមូលពន្ធលើអចលនទ្រព្យរបស់អគ្គនាយកដ្ឋានពន្ធដារ» រួចមកហើយ ដើម្បីឱ្យការប្រមូលពន្ធលើអចលនទ្រព្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ក្រុមខ្ញុំបាទ/នាងខ្ញុំ បានលើកឡើងនូវអនុសាសន៍ល្អៗដែរមានដូចខាងក្រោម ៖

- អគ្គនាយកដ្ឋានពន្ធដារគួរតែមានការបណ្តុះបណ្តាលបន្ថែមទៀតដើម្បីផ្តល់ព័ត៌មានឱ្យអ្នកជាប់ពន្ធនៅក្នុងសង្គមមានការយល់ដឹងកាន់តែច្បាស់។
- អគ្គនាយកដ្ឋានពន្ធដារគួរតែបញ្ជូនមន្ត្រីទៅសិក្សាបន្ថែមទៀត ដើម្បីសម្រួលដល់ការបម្រើសេវាកម្មជូនអ្នកជាប់ពន្ធកុំឱ្យពួកគាត់ត្រូវចំណាយពេលវេលាយូរក្នុងការបង់ពន្ធ។
- អគ្គនាយកដ្ឋានពន្ធដារគួរតែផ្សព្វផ្សាយពីរយៈពេលនៃការបង់ពន្ធ និងពង្រឹងច្បាប់សារពើពន្ធ តាមរយៈបណ្តាញសង្គមដូចជា Facebook YouTube និង Telegram ដើម្បីឱ្យអ្នកជាប់ពន្ធទៅបង់ពន្ធឱ្យទាន់ពេលវេលាដែលបានកំណត់។
- អគ្គនាយកដ្ឋានពន្ធដារគួរតែពង្រឹងព័ត៌មានស្តី អំពីការប្រមូលពន្ធឱ្យកាន់តែច្បាស់លាស់បន្ថែមទៀតជូនដល់អ្នកជាប់ពន្ធ (ព្រោះអ្នកជាប់ពន្ធមួយចំនួនតូចដែល មិនទាន់យល់ជាក់លាក់ច្បាស់ អំពីកាតព្វកិច្ចរបស់ខ្លួនជាហេតុដែលធ្វើឱ្យមានការភាន់ច្រឡំ បង្កើតបានជាភាពមិនពេញចិត្តនិងការគេចវេសមិនព្រមបង់ពន្ធ) តាមរយៈការបើកវគ្គបណ្តុះបណ្តាលឬសិក្ខាសាលាស្តីអំពី ការបង់ពន្ធទៅលើអចលនទ្រព្យឱ្យច្បាស់លាស់បន្ថែមទៀតដើម្បីឱ្យមន្ត្រីដកហូតពន្ធនិងប្រជាជនកាន់តែមានភាពងាយស្រួលក្នុងការអនុវត្តន៍នឹងយល់កាន់តែច្បាស់ ជៀសវាងពេលបង់ពន្ធធ្វើឱ្យមានការខុសឆ្គង។

# ឯកសារយោង

# ឯកសារយោង


- ប្រវត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ
- ចក្ខុវិស័យ បេសកកម្ម គោលដៅ របស់អគ្គនាយកដ្ឋានពន្ធដារ
- រចនាសម្ព័ន្ធនៃការប្រមូលពន្ធ
- តួនាទីនិងភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ
- មូលដ្ឋាននិងនីតិវិធីក្នុងការប្រមូលពន្ធលើអចលនទ្រព្យ
- របាយការណ៍ប្រមូលពន្ធលើអចលនទ្រព្យ
- កាតព្វកិច្ចនៃការបង់ពន្ធ
- ការប្រមូលពន្ធបានផ្តល់ផលប្រយោជន៍ដល់សង្គមនិងសេដ្ឋកិច្ចជាតិ
- ការស្រាវជ្រាវបន្ថែមពីឯកសារខ្លះៗ ដែលពាក់ព័ន្ធទៅ និងពន្ធលើអចលនទ្រព្យតាមការខ្ចីគំរូសារណា សិស្សច្បងពីបណ្ណាល័យនៃវិទ្យាស្ថានវ៉ាន់ដា
- កិច្ចពិភាក្សាជាមួយអ្នកគ្រូ និងមានការពន្យល់ណែនាំអំពីអ្នកគ្រូដឹកនាំសារណា
- http://www.rfi.fr/
- http://www.tax.gov.kh
- https://www.tax.gov.kh/attachments/GDT-Structure.pdf
- https://www.facebook.com/share/1tuQghKbQFHWYvvb/?mibextid=WC7FNe
- https://www.realestate.com.kh/km/news/question-and-answer-on-property-tax-in-cambodia/
- http://www.tax.gov.kh
- https://www.tax.gov.kh/u6rhf7ogbi6/gdtstream/d727f083-1474-45e6-82f3-4f6adef6fe7a
- https://www.rfi.fr/km/cambodia/20140721-

# ឧបសម្ព័ន

# ឧបសម្ព័ន្ធ

- សំណាច់អគារ អគ្គនាយកដ្ឋានពន្ធដារពន្ធដារ



- **ទីតាំង**



Busy area
Cambodia
ផ្លូវអាស៊ានលេខ១១
Busy area
SANGKAT TUEK L'AK TI PIR
សង្កាត់ ទឹកល្អក់ទី ២
Depo Market
Orussey Market
National Olympic Stadium
Lucky Star 2
សណ្ឋាគារ ឡាក់គីស្តារ ២
SANGKAT BOENG SALANG
សង្កាត់ បឹងសាឡាង
St 163
Tuol Sleng Genocide Museum
KHMER-SOVIET FRIENDSHIP...

- **រចនាសម្ព័ន្ធគ្រប់គ្រង**



## រចនាសម្ព័ន្ធស្ថាប័ន

## រចនាសម្ព័ន្ធនៃការគ្រប់គ្រង

- **ឯកឧត្តម គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ
- **ឯកឧត្តម អ៊ុំ សីហា** អគ្គនាយករង
- **ឯកឧត្តម ជាប ដារុន** អគ្គនាយករង
- **ឯកឧត្តម ម៉ិញ បានកុសល** អគ្គនាយករង
- **ឯកឧត្តម កែន សម្បត្តិ** អគ្គនាយករង
- **ឯកឧត្តម ហេង សុខណាង** អគ្គនាយករង
- **លោកជំទាវ ប៊ុន នារី** អគ្គនាយករង
- **ឯកឧត្តម វ័ត្ត មុនី** អគ្គនាយករង
- **លោក លីម ដឹលុច** អគ្គនាយករង
- **ឯកឧត្តម លីម ហ៊ុយជីវ** អគ្គនាយករង

- **ពាក់ស្នើសុំចុះបញ្ជីឬធ្វើបច្ចុប្បន្នភាពអចលនទ្រព្យសម្រាប់ការបង់ពន្ធ**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
MINISTRY OF ECHONOMY AND FINANCE
អគ្គនាយកដ្ឋានពន្ធដារ
GENERAL DEPARTMENT OF TAXATION

ទម្រង់ FORM PT 03

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

សម្រាប់បិទបាកូដ
Stick Barcode Here

## ពាក្យស្នើសុំធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់ម្ចាស់អចលនទ្រព្យ
APPLICATION FORM FOR UPDATING TAX PAYER INFORMATION

### I. ព័ត៌មានម្ចាស់អចលនទ្រព្យ / PROPERTY OWNER INFORMATION

នាមត្រកូល និងនាមខ្លួន Surname and name ______ នាមត្រកូល និងនាមខ្លួនជាអក្សរឡាតាំង Surname and name in Latin ______

ភេទ Sex ☐ ប្រុស Male ☐ ស្រី Female ថ្ងៃខែឆ្នាំកំណើត Date of Birth ______ ទូរស័ព្ទចល័ត Mobile Phone ______

សារអេឡិចត្រូនិក (បើសិនមាន) Email (If any) ______ លេខអត្តសញ្ញាណប័ណ្ណ ឬលេខលិខិតឆ្លងដែន Identification card number or Passport number ______

ផ្ទះលេខ / អគារ House No / Building ______ ផ្លូវ Street ______ ភូមិ Village ______

ឃុំ / សង្កាត់ Commune ______ ក្រុង/ស្រុក/ខណ្ឌ District ______ ខេត្ត/រាជធានី Province/City ______

### II. ព័ត៌មានអចលនទ្រព្យ / PROPERTY INFORMATION

លេខអត្តសញ្ញាណកម្មអចលនទ្រព្យ Property Identification Number (PIN) ______ - ______

លេខអត្តសញ្ញាណកម្មអចលនទ្រព្យ Property Identification Number (PIN) ______ - ______

លេខអត្តសញ្ញាណកម្មអចលនទ្រព្យ Property Identification Number (PIN) ______ - ______

### III. តំណាងអ្នកជាប់ពន្ធ / PROPERTY OWNER REPRESENTATIVE

នាមត្រកូល និងនាមខ្លួន Surname and name ______ នាមត្រកូល និងនាមខ្លួនជាអក្សរឡាតាំង Surname and name in Latin ______

ទូរស័ព្ទចល័ត Mobile Phone ______ លេខអត្តសញ្ញាណប័ណ្ណ ឬលេខលិខិតឆ្លងដែន Identification card number or Passport number ______

ផ្ទះលេខ / អគារ House No / Building ______ ផ្លូវ Street ______ ភូមិ Village ______

ឃុំ / សង្កាត់ Commune ______ ក្រុង/ស្រុក/ខណ្ឌ District ______ ខេត្ត/រាជធានី Province/City ______

### សេចក្តីប្រកាស / DECLARATION

ខ្ញុំបាទ/នាងខ្ញុំសូមធានាថារាល់ឯកសារ និងព័ត៌មានដែលបានបំពេញខាងលើ និងភ្ជាប់នៅក្នុងពាក្យស្នើសុំខាងលើនេះពិតជាត្រឹមត្រូវ ប្រសិនបើមិនពិត ខ្ញុំបាទ/នាងខ្ញុំសូមទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។ I declare that information provided in this application including all attachments is true and correct.

### សំណុំឯកសារភ្ជាប់ / ATTACHMENT CHECK-LIST

☐ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំបុត្របញ្ជាក់កំណើត ឬលិខិតឆ្លងដែនសម្រាប់ជនជាតិបរទេស ឬសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ទីលំនៅ។ Cambodia identification card, Passport, Family record, Residence book or residence letters — ច្បាប់ចម្លង Copy

▶ ☐ ម្ចាស់អចលនទ្រព្យ / Property owner និង/ឬ ☐ តំណាងអ្នកជាប់ពន្ធ / Property owner representative

☐ លិខិតប្រគល់សិទ្ធិ (យោងប្រកាសលេខ ៤៩៣ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០) Authorization letter

សម្រាប់មន្ត្រីពន្ធដារ / Tax official use only

ហត្ថលេខា Signature ______ កាលបរិច្ឆេទ/Date ______ លេខសម្គាល់មន្ត្រី/ID Number ______

កាលបរិច្ឆេទ/Date ______ ហត្ថលេខា ឬស្នាមមេដៃ Signature or thumb print ______

ទម្រង់ FORM PTI 01 - B

# ព័ត៌មានបន្ថែមអចលនទ្រព្យ
# ADDITIONAL INFORMATION FOR PROPERTY

## I- ព័ត៌មានអចលនទ្រព្យ / PROPERTY INFORMATION

**5-** លេខអត្តសញ្ញាណកម្មអចលនទ្រព្យ Property ID Number (PIN)

| | | | | | |
|---|---|---|---|---|---|
| ផ្ទះលេខ/អគារ House N°./Building | | ផ្លូវ Street | | ភូមិ Village | |
| ឃុំ/សង្កាត់ Commune | | ក្រុង/ស្រុក/ខណ្ឌ District | | ខេត្ត/រាជធានី Province/City | |
| ទូរស័ព្ទចល័ត Mobile telephone | | | | | |

**6-** លេខអត្តសញ្ញាណកម្មអចលនទ្រព្យ Property ID Number (PIN)

| | | | | | |
|---|---|---|---|---|---|
| ផ្ទះលេខ/អគារ House N°./Building | | ផ្លូវ Street | | ភូមិ Village | |
| ឃុំ/សង្កាត់ Commune | | ក្រុង/ស្រុក/ខណ្ឌ District | | ខេត្ត/រាជធានី Province/City | |
| ទូរស័ព្ទចល័ត Mobile telephone | | | | | |

**7-** លេខអត្តសញ្ញាណកម្មអចលនទ្រព្យ Property ID Number (PIN)

| | | | | | |
|---|---|---|---|---|---|
| ផ្ទះលេខ/អគារ House N°./Building | | ផ្លូវ Street | | ភូមិ Village | |
| ឃុំ/សង្កាត់ Commune | | ក្រុង/ស្រុក/ខណ្ឌ District | | ខេត្ត/រាជធានី Province/City | |
| ទូរស័ព្ទចល័ត Mobile telephone | | | | | |

**8-** លេខអត្តសញ្ញាណកម្មអចលនទ្រព្យ Property ID Number (PIN)

| | | | | | |
|---|---|---|---|---|---|
| ផ្ទះលេខ/អគារ House N°./Building | | ផ្លូវ Street | | ភូមិ Village | |
| ឃុំ/សង្កាត់ Commune | | ក្រុង/ស្រុក/ខណ្ឌ District | | ខេត្ត/រាជធានី Province/City | |
| ទូរស័ព្ទចល័ត Mobile telephone | | | | | |

**9-** លេខអត្តសញ្ញាណកម្មអចលនទ្រព្យ Property ID Number (PIN)

| | | | | | |
|---|---|---|---|---|---|
| ផ្ទះលេខ/អគារ House N°./Building | | ផ្លូវ Street | | ភូមិ Village | |
| ឃុំ/សង្កាត់ Commune | | ក្រុង/ស្រុក/ខណ្ឌ District | | ខេត្ត/រាជធានី Province/City | |
| ទូរស័ព្ទចល័ត Mobile telephone | | | | | |

**10-** លេខអត្តសញ្ញាណកម្មអចលនទ្រព្យ Property ID Number (PIN)

| | | | | | |
|---|---|---|---|---|---|
| ផ្ទះលេខ/អគារ House N°./Building | | ផ្លូវ Street | | ភូមិ Village | |
| ឃុំ/សង្កាត់ Commune | | ក្រុង/ស្រុក/ខណ្ឌ District | | ខេត្ត/រាជធានី Province/City | |
| ទូរស័ព្ទចល័ត Mobile telephone | | | | | |

**11-** លេខអត្តសញ្ញាណកម្មអចលនទ្រព្យ Property ID Number (PIN)

| | | | | | |
|---|---|---|---|---|---|
| ផ្ទះលេខ/អគារ House N°./Building | | ផ្លូវ Street | | ភូមិ Village | |
| ឃុំ/សង្កាត់ Commune | | ក្រុង/ស្រុក/ខណ្ឌ District | | ខេត្ត/រាជធានី Province/City | |
| ទូរស័ព្ទចល័ត Mobile telephone | | | | | |

កាលបរិច្ឆេទ Date: ថ្ងៃ | ខែ | ឆ្នាំ

ហត្ថលេខា ឬស្នាមមេដៃ Signature or thumb print

ឈ្មោះ Name

**ទម្រង់ FORM PTI 01**

សម្រាប់បិទបាកូដ
Stick bar code here!

Reset form

# ពាក្យស្នើសុំធ្វើប័ណ្ណសម្គាល់ការបង់ពន្ធអចលនទ្រព្យ
# APPLICATION FORM FOR PROPERTY TAX IDENTIFICATION CARD

☐ ខ្ញុំបាទ/នាងខ្ញុំ សូមធ្វើប័ណ្ណសម្គាល់ការបង់ពន្ធលើអចលនទ្រព្យ ដើម្បីងាយស្រួល ដោយមិនចាំបាច់បំពេញលិខិតប្រកាស នៅឆ្នាំក្រោយៗទៀត ហើយយល់ព្រមបង់តម្លៃ ៥០០០រៀល។
I apply and agree to pay 5000 riels for this card used for tax declaration without completing any form for upcoming year.

## I- ព័ត៌មានអចលនទ្រព្យ / PROPERTY INFORMATION

1- លេខអត្តសញ្ញាណកម្មអចលនទ្រព្យ Property ID Number (PIN)

| | | | | | |
|---|---|---|---|---|---|
| ផ្ទះលេខ/អគារ House N°/Building | | ផ្លូវ Street | | ភូមិ Village | |
| ឃុំ/សង្កាត់ Commune | | ក្រុង/ស្រុក/ខណ្ឌ District | | ខេត្ត/រាជធានី Province/City | |
| ទូរស័ព្ទចល័ត Mobile telephone | | | | | |

2- លេខអត្តសញ្ញាណកម្មអចលនទ្រព្យ Property ID Number (PIN)

| | | | | | |
|---|---|---|---|---|---|
| ផ្ទះលេខ/អគារ House N°/Building | | ផ្លូវ Street | | ភូមិ Village | |
| ឃុំ/សង្កាត់ Commune | | ក្រុង/ស្រុក/ខណ្ឌ District | | ខេត្ត/រាជធានី Province/City | |
| ទូរស័ព្ទចល័ត Mobile telephone | | | | | |

3- លេខអត្តសញ្ញាណកម្មអចលនទ្រព្យ Property ID Number (PIN)

| | | | | | |
|---|---|---|---|---|---|
| ផ្ទះលេខ/អគារ House N°/Building | | ផ្លូវ Street | | ភូមិ Village | |
| ឃុំ/សង្កាត់ Commune | | ក្រុង/ស្រុក/ខណ្ឌ District | | ខេត្ត/រាជធានី Province/City | |
| ទូរស័ព្ទចល័ត Mobile telephone | | | | | |

4- លេខអត្តសញ្ញាណកម្មអចលនទ្រព្យ Property ID Number (PIN)

| | | | | | |
|---|---|---|---|---|---|
| ផ្ទះលេខ/អគារ House N°/Building | | ផ្លូវ Street | | ភូមិ Village | |
| ឃុំ/សង្កាត់ Commune | | ក្រុង/ស្រុក/ខណ្ឌ District | | ខេត្ត/រាជធានី Province/City | |
| ទូរស័ព្ទចល័ត Mobile telephone | | | | | |

▶ បើសិនមានអចលនទ្រព្យលើសពី ៤អចលនទ្រព្យ ឡើងទៅ សូមបំពេញទម្រង់បន្ថែមនៅក្នុងទម្រង់ PTI - B / If there are more than 4 properties, please fill additional form PTI - B

## II- ព័ត៌មានអ្នកស្នើសុំប័ណ្ណ / APPLICANT INFORMATION

| | | | |
|---|---|---|---|
| ឈ្មោះ Name | | ឈ្មោះជាអក្សរឡាតាំង Name in Latin | |
| ទូរស័ព្ទចល័ត Mobile phone | | សារអេឡិកត្រូនិក Email | |

**សម្រាប់មន្ត្រី / Official use only**

| | | | |
|---|---|---|---|
| ចំនួនប័ណ្ណ Total card | | ចំនួនទឹកប្រាក់សរុប Total Amount | ៛ |
| បង់ចូលធនាគារ Pay to bank | | | |
| លេខគណនី Account number | | | |
| កាលបរិច្ឆេទ Date | | | |
| ហត្ថលេខា Signature | | | |
| ឈ្មោះ Name | | | |
| លេខសម្គាល់ ID number | | | |

| | |
|---|---|
| កាលបរិច្ឆេទ Date | |
| ហត្ថលេខា ឬស្នាមមេដៃ Signature or thumb print | |
| ឈ្មោះ Name | |

- **ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

GENERAL DEPARTMENT OF TAXATION

**ប័ណ្ណសម្គាល់ការចុះបញ្ជីពន្ធដារ**

TAX REGISTRATION IDENTIFICATION CARD

ឈ្មោះសហគ្រាស : ត្តិសនី

Name in Latin : KANG AKISNY

លេខអត្តសញ្ញាណកម្មសារពើពន្ធ (TIN) : E002-2100

សាខាពន្ធដារខណ្ឌចំការមន / Chamkar Mon Tax Branch

ថ្ងៃខែឆ្នាំចុះបញ្ជី / Registered Date : ០៨ កក្កដា ២០២១ / 08 Jul 2021

-ប័ណ្ណសម្គាល់នេះសម្រាប់ប្រើប្រាស់ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ។

-ត្រូវបង្ហាញប័ណ្ណសម្គាល់នេះគ្រប់ពេលបង់ពន្ធ ឬនៅពេលនាំចូលទំនិញ។

ត្រូវបង្ហាញប័ណ្ណសម្គាល់នេះជូនមន្ត្រីរាជការពន្ធដារនៅពេលដែលមានការចុះត្រួតពិនិត្យកិច្ចការសារពើពន្ធ។

-ករណីបាត់ ឬខូច ត្រូវរាយការណ៍ជូនអគ្គនាយកដ្ឋានពន្ធដារដើម្បីធ្វើថ្មី។

GDTREG2

អគ្គនាយកដ្ឋានពន្ធដារ អាគារកែងមហាវិថីសហព័ន្ធរុស្ស៊ី និងម៉ៅសេទុង សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ (+855) 23 886 708 ទូរសារ (+855) 23 886 700
Email: gdt@tax.gov.kh Website: www.tax.gov.kh

- **អ្នកជាប់ពន្ធ**

ប្រភេទនៃអ្នកជាប់ពន្ធក្នុងប្រទេសកម្ពុជា

## តាមរបបស្វ័យប្រកាស ( ២០២១ ថ្មី )

Cambo Finance

| ប្រភេទអ្នកជាប់ពន្ធ | ប្រភេទក្រុមហ៊ុន (Type of Company) | ទំហំផលរបរប្រចាំឆ្នាំ (Annual Turnover) |
|---|---|---|
| អ្នកជាប់ពន្ធតូច | ក្នុងវិស័យកសិកម្ម សេវាកម្ម និងពាណិជ្ជកម្ម | ២៥០ លាន-១ពាន់លានរៀល (រឺ $៦២,៥០០០- $២៥០,០០០ ) |
| | ក្នុងវិស័យឧស្សាហកម្ម | ២៥០លាន-១,៦ពាន់លានរៀល (រឺ $៦២,៥០០០- $៤០០,០០០) |
| | អ្នកចូលរួមដេញថ្លៃ ឬសួងថ្លៃភាសុី | - |
| អ្នកជាប់ពន្ធមធ្យម | ក្នុងវិស័យកសិកម្ម | ១០០០ លាន-៤០០០ លានរៀល (រឺ $២៥០,០០០- $១,០០០,០០០) |
| | ក្នុងវិស័យសេវាកម្ម និងពាណិជ្ជកម្ម | ១០០០លាន-៦០០០ លានរៀល (រឺ $២៥០,០០០- $១,៥០០,០០០) |
| | ក្នុងវិស័យ ឧស្សាហកម្ម | ១៦០០លាន-៨០០០ លានរៀល (រឺ $៤០០,០០០- $២,០០០,០០០) |
| | ការិយាល័យតំណាង (Representative Office) ឬ NGOs ឬបេសកម្មទូតនិងកុងស៊ុលបរទេស | - |
| អ្នកជាប់ពន្ធធំ | ក្នុងវិស័យកសិកម្ម | លើសពី ៤ពាន់លានរៀល ( រឺ>$១,០០០,០០០) |
| | ក្នុងវិស័យសេវាកម្ម និងពាណិជ្ជកម្មឧស្សាហកម្ម | លើសពី ៦ពាន់លានរៀល ( រឺ> $១,៥០០,០០០) |
| | ក្នុងវិស័យ ឧស្សាហកម្ម | លើសពី ៨ពាន់លានរៀល ( រឺ> $២,០០០,០០០) |
| | ជាបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនពហុជាតិ (Subsidiary Companies) ឬជាគម្រោងវិនិយោគQIP (Qualified Investment Project) | - |

(ផលរបរ សំដៅដល់ថ្លៃនៃការផ្គត់ផ្គង់ទំនិញ ឬសេវាកម្មដែលជាសកម្មភាពអាជីវកម្មរបស់អ្នកជាប់ពន្ធ)

# ប្រភេទនៃអ្នកជាប់ពន្ធក្នុងប្រទេសកម្ពុជា

# តាមទំហំទ្រព្យសកម្ម (២០២១ ថ្មី)

Cambo Finance

(ករណីព័ត៌មានផលរបរជាក់ស្តែងមិនត្រឹមត្រូវតាមផលរបរជាក់ស្តែងរបស់អ្នកជាប់ពន្ធ ការអនុវត្តពន្ធ ត្រូវធ្វើតាមចំណាត់ថ្នាក់របស់ អ.ព.ដ)

| ប្រភេទអ្នកជាប់ពន្ធ | ប្រភេទក្រុមហ៊ុន (Type of Company) | ទ្រព្យសកម្មប្រចាំឆ្នាំ (Asset) |
|---|---|---|
| អ្នកជាប់ពន្ធតូច | ក្នុងវិស័យកសិកម្ម សេវាកម្ម និងពាណិជ្ជកម្ម | ២០០ លាន-១ ពាន់លានរៀល (រឺ $៥០,០០០- $២៥០,០០០ ) |
| | ក្នុងវិស័យឧស្សាហកម្ម | ២០០លាន-២ ពាន់លានរៀល (រឺ $៥០,០០០- $៥០០,០០០) |
| អ្នកជាប់ពន្ធមធ្យម | ក្នុងវិស័យកសិកម្ម សេវាកម្ម និងពាណិជ្ជកម្ម | ១ ពាន់លាន-២ ពាន់លានរៀល (រឺ $២៥០,០០០- $៥០០,០០០) |
| | ក្នុងវិស័យ ឧស្សាហកម្ម | ២ ពាន់លាន-៤ពាន់លានរៀល (រឺ $៥០០,០០០- $១,០០០,០០០) |
| អ្នកជាប់ពន្ធធំ | ក្នុងវិស័យកសិកម្ម សេវាកម្ម និងពាណិជ្ជកម្ម | លើសពី ២ពាន់លានរៀល ( រឺ>$ ៥០០,០០០) |
| | ក្នុងវិស័យឧស្សាហកម្ម | លើសពី ៤ពាន់លានរៀល ( រឺ> $១,០០០,០០០) |

ប្រភពព័ត៌មានចេញពី៖ (ប្រកាសស្តីពីការកែសម្រួលចំណាត់ថ្នាក់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសលេខ ០០៩សហវ. ប្រក ចុះថ្ងៃទី១២ មករា ឆ្នាំ២០២១)

(ទ្រព្យសកម្ម ជាតម្លៃនៃទ្រព្យសម្បត្តិផ្សេងៗ ដែលអ្នកជាប់ពន្ធបានយកទៅប្រើប្រាស់ក្នុងអាជីវកម្ម រួមមាន ទ្រព្យសកម្មរយៈពេលខ្លី និងទ្រព្យសកម្មរយៈពេលវែង)

- **ប្រភេទនៃពន្ធលើអចលនទ្រព្យ**










HOME LONE
1000

# ពន្ធលើការជួល
# អចលនទ្រព្យ





KAMPU
Business

- ផលប្រយោជន៍នៃការប្រមូលពន្ធលើអចលនទ្រព្យ



